Il fallait un budget important pour le développement d'une stratégie de réduction de la pauvreté urbaine car les habitants à reloger sont souvent économiquement très vulnérables. Un fonds de crédit a donc été constitué et sa gestion a été confiée par les autorités publiques à l'organisation UPDF (Urban Poor Development Fund) en collaboration avec l'Asian Coalition for Housing Rights. Cela a été possible car les actions de la municipalité de Phnom Penh ont été menées en étroite collaboration avec UN Habitat, les ONG, le secteur privé et les communautés d'habitants avec l'aide du Programme de Nation Unies pour le développement (PNUD) et le département de développement international du gouvernement anglais.

2/ Après les réinstallations, les problèmes auxquels les personnes sont confrontées proviennent de leur grande pauvreté. Les sites de relocalisation manquent d'assainissement, d'eau potable, d'électricité, d'écoles et de services de base. Cela leur donne le sentiment d'être abandonnés par le gouvernement. C'est pourquoi l'accompagnement des populations relocalisées par les associations communautaires qui font le lien avec les autorités locales est important pour la réussite de ces actions.

3/ Les communautés d'habitants après s'être organisées, ont été reconnues par le ministère de l'Intérieur, en tant que village légal pouvant bénéficier des budgets locaux et leurs habitants jouir de leurs droits civiques tels que la régularisation des papiers d'identité et le droit de vote.

4/ Le travail coordonné entre tous les acteurs a été la solution pour mettre en œuvre une stratégie acceptable et acceptée par tous. Cela a permis d'établir un climat de confiance avec les organisations internationales qui aident à la réduction de la pauvreté par «l'accès de tous à un logement pérenne».

5/ Jusqu'à aujourd'hui, le gouvernement cambodgien et la municipalité consacrent un budget non négligeable chaque année à la relocalisation des populations pauvres pour leur bonne intégration dans la société.

Quartier d'habitat précaire avant et après reconstruction.

Precarious housing district before and after rebuilding.

សង្កាត់ផ្ទះ
សម្បែងមិនមាំទាំ
មុននិងក្រោយ
ការកសាងឡើងវិញ

After 1993, housing arrangements for returning refugees and impoverished communities

1979, return of the population to Phnom Penh; 1992, return of the refugees; 2000, thousands of families in insecure housing; targeted and coordinated policy to rehouse impoverished communities. **BY S.E. MAN CHOEUN**

THE RETURN OF THE POPULATION

City-dwellers who were deported to agricultural cooperatives suffered particularly badly under the Khmer Rouge regime. Many died of hunger and disease, or were executed, between 1975 and 1979.
After 1979 and up to 1991, two categories of refugees were arriving in Phnom Penh. One consisted of former inhabitants of the city who had been evacuated in 1975. The others were people who had been displaced from one province to another, and were passing through the city before returning to their home villages. Phnom Penh therefore became a place of transit and encounter for the whole population, as people tried to find lost family members and friends. The city was a place where they could potentially obtain information, investigate rumours, sort out what was true and what was false. Every piece of information on family, friends or relations might bring hope or despair. People wrote messages on the walls to make contact and find each other. The walls of the buildings at the intersections of big boulevards like Monivong or Sihanouk were used as noticeboards. People left messages at specific places linked with their personal history.
After the signature of the Paris Peace Agreements in October 1991, there was a huge influx of people from the countryside to Phnom Penh. Profoundly poor, they settled in public spaces, along railway lines, on road embankments and the sides of drainage channels, even in dangerous areas like flood-prone riverbanks. Informal neighbourhoods developed quickly. People settled too on the flat roofs of buildings and anywhere where it was possible to build a straw hut or a small house with makeshift materials.
It was only now that the administrative management of the population began, with the appearance of housing registers and a census.
Moreover, during the period when the country was under UNTAC administration, from 1991 to 1993, the refugee repatriation and resettlement programme brought all the refugees into Phnom Penh before redirecting them to the rural areas. Though financial compensation was offered to resettle in the provinces, most of the people who came from the refugee camps would remain permanently in Phnom Penh. As a result, more and more people were arriving and staying in the city.
After 1979, on their return to Phnom Penh, the survivors had easily found places to live, because all the buildings were empty. Some 500,000 people thus settled there between 1979 and 1991. For this second contingent that arrived after 1991, fewer dwellings were available and access to them became more selective and restricted because of the re-establishment of private ownership in 1989, which once again made it possible to buy and sell property and land.
Following the arrival of the United Nations and the international organisations, substantial amounts of cash flowed into the economy and the demand for accommodation for their personnel reactivated the real estate market. As a result, two kinds of transaction existed in parallel: direct sales of property in return for cash, and a barter system, in which real estate was exchanged for precious metals or stones. This two-speed system quickly led to the proliferation of areas of insecure and squalid housing, which were home to the most impoverished communities, which had no access to the "official" real estate market.
A survey conducted in 2009 by the city of Phnom Penh in partnership with local NGOs shows that, in 1993, the populations returning from the refugee camps still had other choices than to live in high-risk areas: only 1.34% of the inhabitants of Phnom Penh had settled along railway lines, 1.16% on the edges of roads, 2.21% on river banks, 0.89% on drainage channels.

IN THE MID-1990S, HOUSING BECOMES A CHALLENGE.

The expansion of illegal housing zones would become a challenge. When the city's entire drain network became blocked and had to be renovated, the first round of renovation work immediately affected people living along the drainage channels and was met with protests. People refused to move and stopped proceedings by blocking machinery access.
Under the government's new plan, if local authorities were planning urban developments on such land, illegal residents had to be evicted and resettled elsewhere with their consent. Phnom Penh municipality had followed the necessary administrative procedures, and decided to use force and deploy bulldozers to demolish houses, actions which in some cases led to confrontations between the authorities and inhabitants. These forced evictions, and the occasional violence that accompanied them, came to a halt following criticisms from Human Rights organisations.
This situation prompted the international agencies to inject more funds into the rehousing of the populations living in public spaces and high-risk areas, since in 2003 almost 60% of insecure housing was still located on land exposed to risk. In fact, in 2002 and 2003, several fires devastated the informal housing areas on the roof of the Tan Pa building (200 families) and on Front du Bassac (3000 families). Urgent action was therefore needed. In 1998, this prompted the governor of Phnom Penh, H.E. Chea Sophara, to ask the Prime Minister to create a specific budget for the acquisition of land outside the city for resettlement sites, and for the construction of homes and schools.
A specific governance arrangement was introduced for these measures, with the creation of a committee made up of donors, NGOs and communities of inhabitants from around Phnom Penh. A coordination strategy and working method were established. The inhabitants organised a community association and a system of micro-credit was set up. In addition, the young architects from the Bureau of Urban Affairs helped to survey the housing plots on the resettlement sites in preparation for the rehousing plans.
The Mean Chey community development project, in 1998, was the first resettlement project, a relocation to the Tuol Svay Prey I sangkat,[1] in the Chamkarmon district. Developed in consultation with the community organisations, this project gained acceptance from the inhabitants for the government's method and the approval of the donor countries and international agencies. This first project was seen as a model and was subsequently duplicated with many other communities, such as Monorom I, Tuol Sombo, Kork Khleang I and Kork Kheang II, Tuol Rakarkos and Chungruk Village, then Anlong Korng.

IN CONCLUSION, WHAT POTENTIAL SOLUTIONS?

1/ Rehousing measures required a significant effort of preparation and implementation. The first stage was to identify which communities were to be rehoused and to understand their specific problems and needs. This process made it

possible to establish statistics, which formed the basis for the resettlement and rehousing programmes. The second stage was to provide information on micro-credit, in order to help families save money to pay for their new accommodation.
A big budget was needed for the development of an urban poverty reduction strategy, because the target populations were often economically very vulnerable. The authorities therefore established a loan fund and assigned its management to the UPDF (Urban Poor Development Fund) in collaboration with the Asian Coalition for Housing Rights. This was possible because Phnom Penh municipality acted in close collaboration with UN Habitat, the NGOs, the private sector and the communities of inhabitants, with the help of the United Nations Development Programme (UNDP) and the British government's Department for International Development.
2/ After the resettlement, the problems people faced came from their extreme poverty. The relocation sites lacked sewage facilities, drinking water, electricity, schools and basic services. This made them feel that they had been abandoned by the government. That is why it is important for the success of such measures that the resettled populations should be supported by community associations working with local authorities.
3/ Once organised, the communities of inhabitants were legally recognised by the Ministry of the Interior as villages, which allowed them to receive local budgets and gave their inhabitants civic rights such as identity papers and the right to vote.
4/ Coordinated work between all the actors involved was the solution needed to implement a strategy that everyone could accept. It established a climate of trust with the international organisations which were helping to reduce poverty by "universal access to a permanent home".
5/ Up to now, the Cambodian government and the municipality have allocated significant annual funds to the resettlement of populations living in poverty and to their integration into society.

1. Sangkat: The sangkat is the smallest administrative subdivision in Phnom Penh

ក្រោយឆ្នាំ១៩៩៣ គ្រប់គ្រងលំនៅដ្ឋានសម្រាប់ការវិលត្រឡប់មកវិញនៃជនភៀសខ្លួននិងប្រជាពលរដ្ឋក្រីក្រ

ឆ្នាំ១៩៩៩ ប្រជាជនវិលត្រឡប់មកភ្នំពេញវិញ ឆ្នាំ១៩៩២ ជនភៀសខ្លួនវិលត្រឡប់មកវិញ ឆ្នាំ២០០០ ប្រជាជនរាប់ពាន់គ្រួសាររស់នៅក្នុងលំនៅដ្ឋានគ្មានសណ្តាប់ធ្នាប់ គោលនយោបាយមួយប្រកបដោយចេតនាខ្ពស់ និងមានការសម្របសម្រួលពីភាគីពាក់ព័ន្ធ នឹងធានាឲ្យប្រជាពលរដ្ឋក្រីក្រមានផ្ទះសម្បែងរស់នៅ។

ដោយឯកឧត្តម ម៉ាន់ ឈឿន

ការវិលត្រឡប់មកវិញរបស់ប្រជាពលរដ្ឋ

ប្រជាពលរដ្ឋរស់នៅក្នុងទីក្រុងដែលត្រូវបានជម្លៀសទៅតាមសហការកសិកម្ម ពិតជាបានទទួលរងទុក្ខវេទនាយ៉ាងខ្លាំងនៅក្នុងរបបខ្មែរក្រហម។ ភាគច្រើននៃពួកគេបានស្លាប់ដោយសារភាពអត់ឃ្លាន ដោយសារជម្ងឺ ឬក៏ត្រូវបានគេយកទៅសម្លាប់ចោល នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩។

ចាប់ពីឆ្នាំ១៩៧៩ និងរហូតដល់ឆ្នាំ១៩៩១ ប្រជាជនពីរប្រភេទបានត្រឡប់មកទីក្រុងភ្នំពេញវិញ មួយប្រភេទគឺអតីតអ្នកភ្នំពេញដែលត្រូវបានជម្លៀសចេញនៅឆ្នាំ១៩៧៥ និងមួយប្រភេទទៀត គឺប្រជាជនដែលត្រូវបានជម្លៀសចេញពីខេត្តមួយទៅខេត្តមួយទៀត និងឆ្លងកាត់ ព្រមទាំងរស់នៅបណ្តោះអាសន្នក្នុងទីក្រុងភ្នំពេញ មុននឹងត្រឡប់ទៅភូមិឃុំកំណើតរបស់ពួកគេវិញ។ ដូច្នេះ នៅពេលនោះ ភ្នំពេញបានក្លាយជាទីតាំងឆ្លងកាត់បណ្តោះអាសន្ន និងជាទីតាំងជំនួបរបស់ប្រជាពលរដ្ឋ ដែលភាគច្រើន បានបាត់បង់សាច់ញាតិ និងស្វះស្វែងរកសមាជិកគ្រួសាររបស់ពួកគេវិញ។ ទីក្រុងគឺជាទីកន្លែងដែលអនុញ្ញាតឲ្យគេទទួលបាននូវប្រភពព័ត៌មាន ផ្ទៀងផ្ទាត់ពាក្យចចាមអារាម និងចម្រាញ់ បែងចែក រវាងព័ត៌មានខុស និងព័ត៌មានត្រូវ។ រាល់ព័ត៌មានពាក់ព័ន្ធនឹងគ្រួសារ មិត្តភក្តិ ឬអ្នកជិតស្និទ្ធរបស់គេ គឺជាប្រភពនៃក្តីសង្ឃឹម ឬអស់សង្ឃឹម។ មនុស្សម្នាសរសេរសារនៅលើជញ្ជាំងផ្ទះ ដើម្បីទាក់ទងគ្នា ឬក៏ណាត់ជួបគ្នា។ ជញ្ជាំងអគារនានាស្ថិតនៅតាមផ្លូវខ្វែងធំៗ ដូចជាមហាវិថីព្រះមុនីវង្ស ឬមហាវិថីព្រះសីហនុជាដើម សុទ្ធតែត្រូវបានគេប្រើជាផ្ទាំងសរសេរសារប្រកាសរកសាច់ញាតិ។ ម្នាក់ៗប្រើប្រាស់ទីតាំងពិសេសផ្សេងៗ ដែលពាក់ព័ន្ធនឹងប្រវត្តិផ្ទាល់ខ្លួនរបស់គេរៀងៗខ្លួន។

បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសត្រូវបាចុះហត្ថលេខានៅខែតុលា ឆ្នាំ១៩៩១ ប្រជាជននៅតាមជនបទបាននាំគ្នាសម្រុកមកទីក្រុងភ្នំពេញយ៉ាងច្រើន។ ដោយសារស្ថិតក្នុងភាពក្រីក្រពេក ពួកគេបានទៅរស់នៅក្នុងដីរដ្ឋ នៅតាមបណ្តោយផ្លូវរថភ្លើង នៅតាមដងផ្លូវ តាមមាត់ប្រឡាយ ឬនៅលើដីដែលអាចបង្ករគ្រោះថ្នាក់ ដូចជាតាមមាត់ទន្លេ ដែលអាចមានទឹកលិចជាដើម។ សង្កាត់ដែលមានផ្ទះសំបែងមិនសូវមាំទាំក៏ចាប់ផ្តើមរីកដុះដាលយ៉ាងលឿន។ គេថែមទាំងទៅសង់ផ្ទះនៅតាមដំបូលអគារចាស់ៗទៀតផង គេសង់ខ្ទមនៅតាមទីតាំងណាដែលអាចសង់បាន ឬក៏សង់កូនផ្ទះដោយប្រើសម្ភារដែលគេរើសយកមកប្រើឡើងវិញ។

ការគ្រប់គ្រងរដ្ឋបាលលើប្រជាពលរដ្ឋ ទើបតែចាប់ផ្តើមនាពេលនោះតែប៉ុណ្ណោះ ដោយយើងបានធ្វើតារាងកត់ត្រានិងធ្វើស្ថិតិប្រជាពលរដ្ឋ។ ជាងនេះទៅទៀត ក្នុងសម័យកាលដែលប្រទេសយើង ស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ អ៊ុន តាក់ ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៣ កម្មវិធីបញ្ជូនជនភៀសខ្លួនត្រឡប់មកវិញ បានប្រមែប្រមូលប្រជាជនទាំងអស់យកមកដាក់ក្នុងទីក្រុងភ្នំពេញ បន្ទាប់មក ទើបបញ្ជូនពួកគេទៅតាមភូមិស្រុកនៅទីជនបទវិញ។ អ្នកទាំងនោះទទួលបានប្រាក់កាសមួយចំនួន ដើម្បីជួយពួកគេឲ្យទៅរស់នៅតាមខេត្តនានា ប៉ុន្តែភាគច្រើននៃអ្នកដែលមកពីជំរំជនភៀសខ្លួន បានបន្តរស់នៅក្នុងទីក្រុងភ្នំពេញ ហើយមិនបានចេញទៅណាទៀតនោះឡើយ។ ដូច្នេះ ប្រជាជនក៏នៅតែបន្តមករស់នៅក្នុងទីក្រុង និងធ្វើមានកំណើនជាប់រហូត។

ក្រោយឆ្នាំ១៩៧៩ នៅពេលដែលពួកគេត្រឡប់មកទីក្រុងភ្នំពេញវិញ អ្នកដែលនៅរស់ ងាយនឹងរកបានផ្ទះសម្រាប់រស់នៅ ពីព្រោះផ្ទះទាំងអស់ក្នុងក្រុងភ្នំពេញសុទ្ធតែនៅទំនេរ។ ប្រជាពលរដ្ឋប្រមាណជា៥០ម៉ឺននាក់ បានចូលមករស់នៅបែបនេះ ក្នុងទីក្រុងភ្នំពេញ ក្នុងចន្លោះពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩១។ ចាប់ពីឆ្នាំ១៩៩១មក មិនសូវមានផ្ទះទំនេរសម្រាប់អ្នកដែលត្រឡប់មកទីក្រុងភ្នំពេញវិញក្នុងរលកទី២ទេ ការរកផ្ទះសម្បែងរស់នៅកាន់តែលំបាក

Panneau montrant les bonnes pratiques à respecter, 2002.

Poster showing good practices to follow, 2002.

ស្លាកសញ្ញាបង្ហាញពីការអនុវត្តល្អៗដែលត្រូវគោរពតាម ឆ្នាំ២០០២

ហើយផ្ទះទំនេរមានកាន់តែតិចទៅ។ ដោយសារ ចាប់ពីឆ្នាំ១៩៨៩មក រដ្ឋ
បានចាប់ផ្តើមដាក់ចេញនូវកម្មសិទ្ធិឯកជន ដែលធ្វើឱ្យប្រជាពលរដ្ឋជាម្ចាស់
មានលទ្ធភាពទិញលក់ផ្ទះសម្បែង និងដីធ្លីរបស់ពួកគេបាន។

ការមកដល់នៃអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា
នឹងធ្វើឲ្យមានចរាចរណ៍រូបិយវត្ថុយ៉ាងច្រើនហើយតម្រូវការផ្ទះសំបែងសម្រាប់
បុគ្គលិករបស់អង្គការសហប្រជាជាតិ នឹងធ្វើឲ្យទីផ្សារអចលនទ្រព្យចាប់ផ្តើម
ដំណើរការឡើងវិញ។ របៀបរបបប្រតិបត្តិការពីរបានប្រព្រឹត្តិទៅទន្ទឹមគ្នា ពោល
គឺការទិញលក់អចលនទ្រព្យដោយប្រើលុយ និងប្រព័ន្ធមួយទៀត គឺការទិញ
លក់ដោយប្រើមាសប្រាក់។ ប្រព័ន្ធទិញលក់ទាំងពីរនេះ នឹងបង្កើនយ៉ាងលឿន
នូវចំនួនតំបន់ដែលមានផ្ទះសម្បែងមិនមាំទាំ និងគ្មានអនាម័យ ហើយនៅក្នុង
តំបន់ទាំងនោះ គឺមានតែប្រជាជនក្រីក្រជាងគេប៉ុណ្ណោះដែលរស់នៅ ពួកគេគ្មាន
លទ្ធភាពទិញផ្ទះក្នុងទីផ្សារអចលនទ្រព្យផ្លូវការនោះឡើយ។

ការសិក្សាស្រាវជ្រាវមួយ ធ្វើឡើងនៅឆ្នាំ២០០៩ ដោយសាលា
ក្រុងភ្នំពេញ សហការដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ បាន
បង្ហាញថា នៅឆ្នាំ១៩៩៣ ប្រជាពលរដ្ឋដែលត្រឡប់មកពីជំរំជនភៀសខ្លួនវិញ
នៅតែមានជម្រើសផ្សេង មិនចាំបាច់ទៅរស់នៅក្នុងដីធ្លីដែលមានហានិភ័យនោះ
ឡើយ៖ មានតែ១,៣៤%នៃប្រជាជនក្នុងទីក្រុងភ្នំពេញប៉ុណ្ណោះដែលបានទៅ
រស់នៅតាមបណ្តោយផ្លូវរថភ្លើង ១,១៦% នៅតាមបណ្តោយផ្លូវថ្នល់ ២,២១%
នៅតាមមាត់ទន្លេ និង០,៨៩% នៅលើលូបង្ហូរទឹកកខ្វក់។

នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ផ្ទះសម្បែងក្លាយជាបញ្ហាប្រឈមមួយ

ការរីកធំនៃតំបន់មានលំនៅស្ថានមិនស្របច្បាប់ បានក្លាយជាបញ្ហា
ប្រឈមមួយ។ ប្រព័ន្ធលូបង្ហូរទឹកទាំងអស់សុទ្ធតែស្ទះ ដូច្នេះ យើងចាំបាច់ត្រូវតែ
ជួសជុលឡើងវិញ។ យុទ្ធនាការអនុវត្តគម្រោងជួសជុលដំបូងបានប៉ះពាល់ភ្លាម
ដល់ប្រជាពលរដ្ឋដែលរស់នៅលើនិងជិតលូ និងបង្កឲ្យមានការធ្វើបាតុកម្មតវ៉ា
ហើយប្រជាពលរដ្ឋបានបដិសេធមិនព្រមចេញ រាវាំងមិនឲ្យការដ្ឋានអាចប្រព្រឹត្តិ
ទៅបាន ដោយរាវាំងមិនឲ្យគ្រឿងចក្រចូលទៅក្នុងការដ្ឋាន។

យោងតាមផែនការថ្មីបង្កើតឡើងដោយរដ្ឋាភិបាល ប្រសិនបើ
សាលាក្រុងគ្រោងអភិវឌ្ឍតំប់គ្មានសណ្តាប់ធ្នាប់ទាំងនេះ ប្រជាពលរដ្ឋដែល
រស់នៅខុសច្បាប់ ត្រូវបណ្តេញចេញ ហើយយកពួកគេទៅរស់នៅកន្លែងផ្សេង
ដោយមានការយល់ព្រមពីពួកគេផងដែរ។ សាលាក្រុងភ្នំពេញបានចាត់វិធាន
ការរដ្ឋបាលចំពោះមុខស្ថានភាពបែបនេះ ហើយបានសម្រេចឲ្យកងកម្លាំងជួយ
អន្តរាគមន៍ និងយកគ្រឿងចក្រទៅឈូសឆាយផ្ទះទាំងអស់ចេញ។ សកម្មភាព
ទាំងនេះ ពេលខ្លះ បាននាំទៅដល់ការប្រឈមមុខដាក់គ្នារវាងអាជ្ញាធរនិង
ប្រជាពលរដ្ឋ។ ការបង្ខំឲ្យប្រជាពលរដ្ឋចេញបែបនេះ ពេលខ្លះ ក៏បង្កឲ្យមាន
អំពើហឹង្សាខ្លះដែរ ដែលត្រូវបានបញ្ឈប់ទៅវិញ បន្ទាប់ពីមានការរិះគន់ពី
សំណាក់អង្គការការពារសិទ្ធិមនុស្ស។ ស្ថានភាពបែបនេះបាននាំឲ្យអង្គការ
អន្តរជាតិនានាគៀរគថវិកាកាន់តែច្រើន ដើម្បីផ្តល់ហិរញ្ញប្បទានលើគម្រោង
សាងសង់ផ្ទះជូនប្រជាពលរដ្ឋដែលរស់នៅតាមទីតាំងសាធារណ: និងលើដី
ដែលអាចបង្កហានិភ័យ ពីព្រោះនៅឆ្នាំ២០០៣ ប្រជាពលរដ្ឋក្រីក្រជិត៦០%
នៅតែបន្តរស់នៅលើដីដែលអាចបង្កហានិភ័យ។

ជាងនេះទៅទៀត នៅឆ្នាំ២០០២ និងឆ្នាំ២០០៣ អគ្គីភ័យជាច្រើន
បានបំផ្លិចបំផ្លាញផ្ទះសម្បែងរបស់ប្រជាពលរដ្ឋក្រីក្រដែលរស់នៅលើដំបូល
អគារ តាន់ប៉ា ចំនួន២០០គ្រួសារ និងនៅតាមមាត់ទន្លេបាសាក់ចំនួន
៣០០០គ្រួសារ។ ដូច្នេះ អាជ្ញាធរត្រូវចាត់វិធានការយ៉ាងបន្ទាន់។ កាលនោះ
គឺឆ្នាំ១៩៩៨ ស្ថានភាពបាននាំឲ្យអភិបាលក្រុងភ្នំពេញនៅសម័យនោះ គឺ
ឯកឧត្តម ជា សុផារ៉ា ធ្វើសំណើលើកដំបូងដល់នាយករដ្ឋមន្ត្រី សុំបង្កើតកញ្ចប់
ថវិកាពិសេសមួយសម្រាប់ទិញដីនៅក្រៅក្រុង ដើម្បីសាងសង់លំនៅដ្ឋាន និង
សាលារៀន ហើយបញ្ជូនប្រជាពលរដ្ឋក្រីក្រទាំងនោះទៅរស់នៅ។ អភិបាលកិច្ច
ពិសេសមួយលើសកម្មភាពការងារទាំងនេះ ត្រូវបានដាក់ចេញដោយមាន
ការបង្កើតឡើងនូវគណ:កម្មាធិការមួយ ដែលមានការចូលរួមពីស្ថាប័នផ្តល់
ជំនួយ អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ប្រជាពលរដ្ឋ ដោយមានសាលា
រាជធានីភ្នំពេញជាអ្នកសម្របសម្រួល។ យុទ្ធសាស្ត្រសម្របសម្រួលមួយ និង
វិធីសាស្ត្រធ្វើការមួយ ត្រូវបានកំណត់។ ប្រជាពលរដ្ឋបាននាំគ្នាបង្កើតជាសមា
គមសហគមន៍ហើយប្រព័ន្ធមីក្រូឥណទានមួយត្រូវបានបង្កើតឡើង។

ម្យ៉ាងវិញទៀត ស្ថាបត្យការវ័យក្មេងនៃការិយាល័យកិច្ចការក្រុង បានជួយធ្វើ
សម្រង់ផ្ទះនៅតាមទីតាំងដែលត្រូវផ្លាស់ប្តូរ ដើម្បីត្រៀមរៀបចំផែនការបញ្ជូន
ប្រជាពលរដ្ឋឲ្យទៅរស់នៅកន្លែងថ្មី។ គម្រោងអភិវឌ្ឍន៍សហគមន៍មានជ័យ នៅ
ឆ្នាំ១៩៩៨ គឺជាគម្រោងបញ្ជូនប្រជាពលរដ្ឋពីកន្លែងចាស់ ឲ្យទៅរស់នៅកន្លែង
ថ្មី លើកទី១ នៅក្នុងសង្កាត់ទួលស្វាយព្រៃ១ ក្នុងខណ្ឌចំការមន។ គម្រោងនេះ
ត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ ឯកភាពជាមួយសមាគម
សហគមន៍ និងបានអនុញ្ញាតឲ្យប្រជាពលរដ្ឋទទួលយកនូវវិធីសាស្ត្រប្រើប្រាស់
ដោយរដ្ឋាភិបាលព្រមទាំងមានការជឿជាក់ពីបណ្តាប្រទេសផ្តល់ជំនួយ និង
អង្គការអន្តរជាតិ។ គម្រោងទី១នេះ ត្រូវបានចាត់ទុកជាគម្រោងគម្រូ ហើយ
បន្ទាប់មក ត្រូវបានយកទៅអនុវត្តដើម្បីជាប្រយោជន៍សហគមន៍ជាច្រើនផ្សេង
ទៀត ដូចជាសហគមន៍មនោរម្យ១ សហគមន៍ទួលសំបូរ សហគមន៍គោកឃ្លាំង
១ និងគោកឃ្លាំង២ សហគមន៍ទួលរកាកោះ ភូមិជង្រុក និងភូមិអន្លង់គង។

សេចក្តីសន្និដ្ឋាន វិធីដោះស្រាយមួយចំនួន

១. រឿងបញ្ជូនប្រជាពលរដ្ឋពីកន្លែងចាស់ទៅរស់នៅកន្លែងថ្មី
តម្រូវឲ្យមានការងារច្រើនក្នុងការត្រៀមរៀបចំ និងអនុវត្ត។ ដំណាក់កាលទី១
 គឺត្រូវស្រង់ចំនួនគ្រួសារប្រជាពលរដ្ឋដែលត្រូវបញ្ជូនឲ្យទៅរស់នៅក្នុងទីតាំងថ្មី
និងស្វែងយល់អំពីបញ្ហា និងតម្រូវការពិសេសរបស់ពួកគាត់។ បញ្ហានេះតម្រូវឲ្យ
យើងធ្វើបញ្ជីស្ថិតិ សម្រាប់ប្រើប្រាស់ជាមូលដ្ឋាននៃការរៀបចំគម្រោងបញ្ជូន
ប្រជាពលរដ្ឋពីកន្លែងចាស់ទៅរស់នៅកន្លែងថ្មី។ ដំណាក់កាលទី២ គឺការងារ
ចលនាប្រជាពលរដ្ឋគ្រប់គ្រួសារ ឲ្យយល់ពីមីក្រូឥណទាន ដើម្បីឲ្យពួកគាត់ចេះ
សន្សំប្រាក់ សម្រាប់ចំណាយលើផ្ទះថ្មី។

យើងត្រូវការថវិកាច្រើន ដើម្បីបង្កើតយុទ្ធសាស្ត្រកាត់បន្ថយភាព
ក្រីក្រក្នុងក្រុង ពីព្រោះប្រជាពលរដ្ឋដែលត្រូវប្តូរទីតាំងឲ្យទៅរស់នៅកន្លែងថ្មី
ជាទូទៅ មានស្ថានភាពហិរញ្ញវត្ថុផុយស្រួយខ្លាំងណាស់។ មូលនិធិឥណទាន
មួយក៏ត្រូវបានបង្កើតឡើង ហើយការគ្រប់គ្រងមូលនិធិនេះ អាជ្ញាធរសាធារណ:
បានប្រគល់ជូនអង្គការ UPDF (Urban Poor Development Fund -
មូលនិធិអភិវឌ្ឍន៍ប្រជាពលរដ្ឋក្រីក្រក្នុងក្រុង) ដោយសហការជាមួយអង្គការ
ACHR (Asian Coalition for Housing Rights - សម្ព័ន្ធភាពអាស៊ាន
ដើម្បីសិទ្ធិមានលំនៅដ្ឋាន)។ កិច្ចការនោះអាចធ្វើទៅបាន សាលាក្រុងភ្នំពេញ
បានសហការយ៉ាងជិតស្និទ្ធជាមួយជាមួយអង្គការ UN Habitat អង្គការ
ក្រៅរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍ប្រជាពលរដ្ឋ ដោយមានជំនួយ
ពីកម្មវិធីអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ (អង្គការ UNDP) និង
នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិរបស់រដ្ឋាភិបាលអង់គ្លេស។

២. បន្ទាប់ពីទៅរស់នៅកន្លែងថ្មីហើយ បញ្ហាដែលប្រជាពលរដ្ឋត្រូវ
ប្រឈម គឺបណ្តាមកពីពួកគាត់មានភាពក្រីក្រខ្លាំងពេក។ ទីតាំងថ្មីនោះនៅ
ខ្វះប្រព័ន្ធលូ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធអគ្គិសនី សាលារៀន និងសេវាមូលដ្ឋាន
ដទៃទៀត។ ស្ថានភាពបែបនោះ នាំឲ្យពួកគាត់មានអារម្មណ៍ថា ត្រូវបាន
រដ្ឋាភិបាលបោះបង់ចោល។ ហេតុដូច្នេះហើយបានជាការជួយជ្រោមជ្រែងដល់
ប្រជាពលរដ្ឋនៅក្នុងទីតាំងថ្មី ដោយសមាគមសហគមន៍ ដែលត្រូវទាក់ទង
អាជ្ញាធរមូលដ្ឋាន គឺសំខាន់ណាស់ ដើម្បីធានាបាននូវជោគជ័យនៃសកម្មភាព
ការងារទាំងនេះ។

៣. ក្រោយពីរៀបចំរួចរាល់ហើយ សហគមន៍ប្រជាពលរដ្ឋត្រូវបាន
ទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ថាជាភូមិមួយស្របច្បាប់ អាចទទួលបាន
ថវិកាមូលដ្ឋាន ហើយប្រជាពលរដ្ឋនៅក្នុងភូមិថ្មីនេះក៏មានសិទ្ធិរដ្ឋប្បវេណីដូច
ប្រជាពលរដ្ឋផ្សេងទៀតដែរ ដូចជាមានលិខិតស្នាមស្របច្បាប់ អត្តសញ្ញាណ
បណ្ណត្រឹមត្រូវ និងមានសិទ្ធិបោះឆ្នោតជាដើម។

៤. ការងារ ដែលសម្របសម្រួលដោយដៃគូពាក់ព័ន្ធទាំងអស់ គឺជា
ដំណោះស្រាយមួយ ដើម្បីអនុវត្តយុទ្ធសាស្ត្រដែលទទួលបានការឯកភាពពីគ្រប់
ភាគីពាក់ព័ន្ធ។ ការងារនេះបានបង្កើតបរិយាកាសមួយប្រកបដោយទំនុកចិត្ត
ជាមួយអង្គការអន្តរជាតិ ដែលជួយកាត់បន្ថយភាពក្រីក្រ តាមរយ:ការផ្តល់ជូន
ប្រជាពលរដ្ឋគ្រប់គ្រួសារ នូវលំនៅដ្ឋានមួយសមរម្យប្រកបដោយនិរន្តរភាព។
៥. រហូតដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា និងសាលាក្រុង បានចំណាយ
ថវិកាជាច្រើនរៀងរាល់ឆ្នាំ សម្រាប់បញ្ជូនប្រជាពលរដ្ឋក្រីក្រទៅរស់នៅក្នុងទីតាំង
ថ្មី ដើម្បីឲ្យពួកគាត់ធ្វើសមាហរណកម្មបានល្អចូលទៅក្នុងសង្គមជាតិវិញ។

La régie des eaux de Phnom Penh, renaissance, réforme & développement durable

Fournir de l'eau potable à tous les habitants, même les plus pauvres, tel a été le défi relevé par la Régie des Eaux de Phnom Penh en mettant en place un mode de gestion exemplaire. **PAR S.E. EK SONN CHAN**

© PPWSA

Chaque famille installe son tuyau d'arrivée d'eau.

Each family installs its water supply pipe.

គ្រួសារនីមួយៗតទុយោទឹកចូលក្នុងផ្ទះរបស់ខ្លួន

En 1975, la période révolutionnaire et génocidaire des Khmers rouges a commencé. La capitale a été entièrement vidée de ses habitants. L'administration Khmère rouge s'y est installée mais durant quatre ans, les installations destinées à l'approvisionnement en eau potable n'ont pratiquement pas fonctionné et il en a résulté un niveau de dégradation élevé. Le régime des Khmers rouges a été chassé de Phnom Penh en 1979 et les habitants ont commencé à revenir dans la ville. Les installations d'eau abandonnées ont été remises en service, mais de manière désorganisée.

DES DÉBUTS TRÈS DIFFICILES

En 1992, la situation était toujours un cauchemar pour tout résident de Phnom Penh. Les installations d'eau étaient encore en grande partie inutilisables. La Régie des Eaux de Phnom Penh (RDE) ne pouvait produire qu'environ 65 000 m³ d'eau potable, soit environ 40% de la capacité de l'installation. Cela ne pouvait desservir que 25% environ des résidents de Phnom Penh. Seule une partie de l'eau distribuée aux ménages, par le biais d'un réseau de distribution en fonte de 288 km, arrivait jusqu'aux immeubles. En effet, les habitants revenus dans la ville ponctionnaient une partie de cet approvisionnement par l'intermédiaire de 1945 puits qu'ils avaient eux-mêmes creusés[1]. Ces puits venaient directement percer les tuyaux d'eau du réseau souterrain. À partir de ces puits improvisés, de petites pompes submersibles étaient installées. On y raccordait des tuyaux flexibles prolongés jusqu'aux fenêtres des appartements pour y acheminer l'eau. Cet enchevêtrement de tuyaux porta alors ce nom fameux de « connexion spaghettis ». Ce système de débrouille que les habitants utilisaient pour se connecter dans les années 80 ne permettait pas au réseau de bien fonctionner car le nombre important de puits, auquel il faut ajouter les fuites, entrainait un fort affaiblissement de la pression dans tout le réseau. Cela empêchait l'acheminement de l'eau jusqu'aux habitations normalement connectées. En outre, le service public ne pouvait récupérer le paiement que de 48% de l'eau produite en raison d'un fichier clients erroné et obsolète, d'une consommation non mesurée, ainsi que d'une faible volonté et de la corruption des collecteurs. Seulement 25% environ de l'eau produite générait des revenus effectivement collectés. Ceci explique pourquoi le service public n'était pas en mesure de rémunérer raisonnablement son personnel. Le salaire à l'époque ne s'élevait qu'à un dollar par jour. Comme la RDE n'a jamais pu payer la facture de l'électricité nécessaire au fonctionnement de l'usine d'eau potable, elle a été déclarée en faillite.

© PPWSA

Des branchements illégaux sont réalisés directement sur le réseau souterrain

Illegal connections are made directly on the underground network.

ការតភ្ជាប់ទឹកដោយខុសច្បាប់ចេញពីប្រព័ន្ធក្រោមដីផ្ទាល់

LA REPRISE EN MAIN

En 1993, la situation était propice au lancement d'une stratégie de réforme. Après les élections générales de Juillet 1993 assistées par l'ONU, le gouvernement élu adopta une stratégie d'économie de marché et le service des eaux devint éligible à l'aide internationale. Le service public a alors reçu des subventions du PNUD, de la France et du Japon pour le renforcement des capacités institutionnelles et des projets d'urgence. J'ai été chargé de diriger la RDE le 11 septembre 1993. Pour faire face à la situation désastreuse précitée, j'ai mis en place un groupe de travail composé

Les travaux d'installation du réseau d'eau potable (PPWSA)

Photographies des familles au moment du raccordement (PPWSA).

ការដ្ឋានតបណ្តាញ ទឹកស្អាត (រដ្ឋាករទឹក ស្វយ័ត ក្រុងភ្នំពេញ)

Photographies des familles au moment du raccordement.

Photographs of families on completion of the connection (PPWSA).

រូបថតគ្រួសារប្រជាពលរដ្ឋក្នុងពេលតទឹក (រដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ)

© PPWSA

d'un personnel jeune, dynamique, éduqué et très motivé. Dans un premier temps, nous nous sommes concentrés sur trois actions principales qui constituaient le plan de relance : (i) changement de culture, (ii) efficacité opérationnelle et (iii) développement durable. Pour changer de culture, nous avons pris la devise des trois mousquetaires : « un pour tous, tous pour un ». Nous suivions aussi le principe suivant : « l'exemple vient d'en haut ». Pour changer l'état d'esprit et motiver les personnels, nous avons formé tous les états-majors, offert une rémunération raisonnable, créé des mesures d'incitation justes et une discipline sans faille accompagnée de sanctions strictes. Pour pouvoir fournir de l'eau à nos populations avec des tarifs abordables, nous savions que nous devions être efficaces dans toutes les opérations. Nous nous sommes concentrés particulièrement sur les économies d'énergie et la réduction des pertes en eau, en particulier les pertes commerciales, en luttant pour éliminer les raccordements illégaux. Pour que le paiement des factures devienne une réalité, nous avons mis à jour en urgence le fichier des abonnés, compté chaque connexion et informatisé le système de facturation dès 1994 au moyen d'une subvention française. Trois ans après le début de notre réforme, la situation a commencé de s'améliorer. Le personnel était motivé pour travailler pour le bien commun. La production augmentait, les pertes en eau diminuaient et les revenus devenaient suffisants pour recouvrer la majeure partie des coûts avec une rémunération raisonnable du personnel. En 1997, le gouvernement a promulgué une loi visant à conférer une autonomie administrative et financière à la RDE qui changea alors de nom et devint la Phnom Penh Water Supply Authority (PPWSA). Comme le tarif de l'eau était de 250 riel/m³ pour les utilisateurs domestiques et de 700 riel/m³ pour les consommateurs commerciaux, ce qui était trop bas par rapport aux coûts de production, le gouvernement a autorisé la PPWSA à réviser son tarif. En janvier 1997, un tarif global de subventions croisées a été décidé puis révisé en janvier 2001. Nous avons toujours pensé que les tarifs devaient refléter à la fois les recettes et l'efficacité des entreprises, tout en restant abordable pour tous.

Pourcentage d'eau non-payée par an

Pourcentage of unpaid water each year

ភាគរយទឹកមិនបានបង់ក្នុងមួយឆ្នាំ

Résultat financier

Financial income

លទ្ធផលហិរញ្ញវត្ថុ

Expansion de la zone desservie par le réseau d'eau (1993-2020)
Expansion of the receiving area with a mains water supply (1993-2020)
ការពង្រីកតំបន់ទឹកស្អាតទៅដល់ (ឆ្នាំ១៩៩៣-ឆ្នាំ២០២០)



Dans cette nouvelle ère, avec l'aide de la France, du Japon, de l'Asian Development Bank et de la Banque Mondiale, nous avons entamé une expansion dynamique de nos opérations dans les domaines de la production, de la distribution et des branchements au réseau de la clientèle, tout en continuant à développer l'efficacité des opérations. Sur une période de 18 ans, nous avons réussi à réduire les pertes en eau de 72% en 1993 à 5,9% en 2012. Au cours de la même période, la base de données des abonnés est passée de 26881 connexions de service à 220000 et le réseau de distribution d'eau de 288 km à 2000 km. De même, la couverture du service de l'eau est passée de 20% à 90% et le taux de recouvrement des recettes a atteint 99,9%. Plus important encore, le personnel de PPWSA a reçu une rémunération beaucoup plus élevée que celle des autres fonctionnaires. PPWSA a finalement réussi à assurer la durabilité de ces résultats.

Progression des branchements des familles pauvres au réseau d'eau potable de 1999 à 2011
Increase in connections of poor families to the drinking water network from 1999 to 2011
ការកើនឡើងនៃតំណភ្ជាប់របស់គ្រួសារក្រីក្រជាមួយប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០១១



DE L'EAU POTABLE POUR TOUS

Bien que nous ayons étendu la couverture des services, nous n'avons jamais délaissé les populations vulnérables. Auparavant, les pauvres avaient très peu de chance d'accéder à l'eau de la ville. Sans raccordement au réseau, ils payaient leur eau beaucoup plus chère que n'importe quel autre citoyen car ils étaient obligés de passer par l'intermédiaire des vendeurs d'eau. À partir de 1999, avec l'aide des donateurs, en particulier de la France via les Fonds de l'Eau (fournis par les agences de l'eau de France) et la Mairie de Paris, PPWSA a pu offrir une réduction de 20% sur les frais de connexion pour les pauvres et permettre le paiement par versements étalés sur 20 mois. En 2003, en raison de résultats financiers positifs et avec l'aide des Fonds de l'eau français, nous avons lancé un nouveau programme intitulé «Eau pour tous» qui subventionnait les frais de raccordement à 30%, 50%, 70% ou 100%, le pourcentage étant basé sur un critère d'évaluation sociale fait par un comité mixte. Nos tarifs ont été réduits grâce à une approche de subventions croisées. En conséquence, plus de 100 communautés d'habitants de Phnom Penh ont eu un accès direct à l'eau potable par le réseau PPWSA. En 2011, plus de 70% des 21 490 connections effectuées était des connections que l'on appelait sociales, car elles étaient destinées en majorité à des familles vulnérables sans moyen, donc subventionnées. Cette politique a eu des effets très importants sur la santé et le bien-être des familles, notamment sur la réduction des épidémies dues aux maladies hydriques. Elle a également permis de libérer des milliers de femmes et d'enfants du fardeau de la recherche quotidienne d'eau.

Enfin, je conclurai en disant que la PPWSA est née d'une situation très difficile, où 20% seulement des ménages pouvaient recevoir de l'eau, et encore de façon intermittente. Elle est maintenant devenue l'un des services d'approvisionnement en eau potable les plus performants de la région. Cette réalisation a été possible pour trois raisons principales: (i) la stabilité sociale et politique et la volonté politique du gouvernement, (ii) l'assistance des partenaires de développement et (iii) la bonne gouvernance «Équitable pour tous, ferme envers les objectifs et Foi envers les dirigeants et subordonnés» mise en œuvre par une équipe engagée, dotée d'un esprit d'entreprise fort et de service public dédié.

1. Diagnostic effectué au début de mon mandat pour recenser tous les trous creusés par comptage.

Phnom Penh Water Supply Authority—revival, reform, and sustainable development

The Phnom Penh Water Supply Authority met the challenge of providing drinking water for all citizens, even the poorest of the poor, by setting up an exemplary management model.

BY S.E. EK SONN CHAN

In 1975 began the revolutionary, genocidal period of the Khmer Rouge. The capital was completely emptied of its habitants. The Khmer Rouge government was headquartered there but for a four-year period, the clean and safe water supply facilities virtually stopped operating, resulting in severe damages. The Khmer Rouge regime was ousted from Phnom Penh in 1979 and people started coming back to the city. The water supply facilities that had been abandoned went back into service but in an uncoordinated manner.

VERY DIFFICULT BEGINNINGS

In 1992, the situation was still a nightmare for all those living in Phnom Penh. Much of the water facilities were unusable. The Phnom Penh Water Supply Board (Régie des Eaux de Phnom Penh) could only provide about 65,000 m^3 of drinking water, around 40% of the system capacity, which could only serve about 25% of Phnom Penh's residents. Only part of the water distributed to the households through a 288-km cast iron water pipe network actually reached the buildings. Indeed, people who had come back to the city were drawing off part of the supply through 1,945 wells which they had dug themselves.[1] These wells were directly hooked to the underground water pipes. Small submersible pumps were put into those improvised wells and hooked up to flexible pipes that brought water all the way to apartment windows. This tangle of pipes was referred to as the "spaghetti connections." This makeshift system used for hookups in the 1980s impeded the smooth functioning of the network because the large number of wells, which led to leakage, greatly reduced the water pressure throughout the network which interfered with getting water to people who were properly hooked up. The Phnom Penh Water Supply Board could also only collect payment on 48% of the water produced because its user list was incorrect and outdated, consumption was not metered, and payment collectors were negligent and corrupt. Only about 25% of the water produced generated actual revenue. The Phnom Penh Water Supply Board was thus unable to pay its staff a decent wage. Salaries at the time came to no more than a dollar a day. The Phnom Penh Water Supply Board was never able to pay the electricity bill to operate its water treatment plant, it went bankrupt.

TAKING BACK CONTROL

In 1993, the situation was favorable to a reform strategy. After the UN-assisted general elections in July 1993, the elected government adopted a market economy and the water department became eligible for international aid. It received grant assistance from the UNPD, France, and Japan for institutional capability development and emergency support.

I was put in charge of the Phnom Penh Water Supply Board on September 11, 1993. To deal with the disastrous situation outlined above, I set up a working group of young, dynamic, educated, and highly motivated people. We initially focused on three aspects of the stimulus package: (i) a culture shift, (ii) operational efficiency and (iii) sustainable development. To operate a culture shift, we focused on the three musketeers' motto: "One for all, all for one." We also followed the principle that we were "leading by example." To change the mindset and motivate staff, we offered training and a decent wage, created incentives and a consistent discipline along with strict sanctions. To supply water to our people at affordable rates, we knew that we had to be efficient in all operations. We paid particular attention to saving energy and reducing water losses, especially business losses, by working to eliminate illegal hookups. To encourage bill payment, we immediately updated the user list, counted every hookup and computerized the billing system in 1994 with French grant aid.

Three years after starting our reform, the situation started to improve. Employees were motivated to work for the common good. Production was increasing, water losses were decreasing, and revenues were meeting most of the costs while offering reasonable staff wages. In 1997, the government enacted a law to give us administrative and financial autonomy, and our name was officially changed to Phnom Penh Water Supply Authority (PPWSA). The rate for water was 250 riels/m^3 for domestic users and 700 riels/m^3 for business consumers. That was too low relative to our production costs, so the government authorized us to revise its rate. In January 1997, an overall rate of cross-subsidies was set then revised in January 2001. We have always felt that the rates should reflect both the receipts and business efficiency, while remaining affordable for all.

In this new era, with assistance from France, Japan, the Asian Development Bank, and the World Bank, we have undertaken a dynamic expansion of our operations in the fields of production, distribution, and user hookup to the network, while continuing to develop operational efficiency. Over a period of 18 years, we have succeeded in reducing water losses from 72% in 1993 to 5.9% in 2012. During the same period, the user database went from 26,881 service connections to 220,000 and the main water network grew from 288 km to 2,000 km. The water department's coverage went from 20% to 90% and the revenue collection rate has reached 99.9%. More importantly, PPWSA staff is paid a much higher salary than other civil servants. PPWSA has finally achieved lasting results.

DRINKING WATER FOR EVERYONE

We have expanded service coverage but have never overlooked vulnerable communities. Previously, the poor had very little chance of getting water from the city. Without being connected to the network, they were paying much more for their water than any other citizen because they had to go through water dealers. Back in 1999, with donor assistance, notably France via the Water Utility Fund (provided by water agencies in France) and Paris City Hall, PPWSA was able to cut by 20% the cost of hookup for poor people and offer 20-month installment payments. In 2003, in view of the positive financial performance and with funding from the French Water Utility Fund, we launched a new program, "Water for All," which provides subsidy assistance for hookup costs up to 30%, 50%, 70% or 100% (the percentage is based on social criteria established by a joint committee). Our rates were cut using the crossed-subsidy approach. As a result, over 100 communities of Phnom Penh residents were able to get direct access to drinking water through the PPWSA network. In 2011, over 70% of the 21,490 hookups were social connections, i.e. mainly provided for vulnerable families without resources thus qualifying for a subsidy. This policy has had a major impact on the health and welfare of the families, notably through the reduction of waterborne diseases. It has also relieved thousands of women and children from the daily burden of fetching water.

Let me conclude by saying that the PPWSA was born of a very challenging situation, where only 20% of households could get water and only intermittently. It has now become one of the most efficient drinking water supply companies of the region. That was possible for three main reasons: (i) social and political stability and political will on the part of the government, (ii) assistance from development partners and (iii) strong governance ("Fair for all, dedicated to its goals, with faith in its leaders and subordinates") implemented by a committed team with a strong entrepreneurial spirit and a dedication to public service.

1. This assessment was made at the beginning of my term in office in order to determine the number of holes that had been dug.

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ៖ ការកើតឡើងវិញ កំណែទម្រង់ និងការអភិវឌ្ឍប្រកបដោយចីរភាព

ផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋគ្រប់រូប ទោះបីជាប្រជាពលរដ្ឋក្រីក្រជាងគេក្តី នោះហើយគឺជាបញ្ហាប្រឈមដែលត្រូវដោះស្រាយដោយរដ្ឋាករទឹកស្វយ័តភ្នំពេញ តាមរយៈការដាក់ចេញនូវវិធីសាស្ត្រគ្រប់គ្រងគម្រូមួយ។

ដោយឯកឧត្តម ឯក ស៊ុនចាន់

នៅឆ្នាំ១៩៧៥ សម័យកាលបដិវត្តន៍ និងប្រល័យពូជសាសន៍ខ្មែរក្រហមបានចាប់ផ្តើមឡើង។ ប្រជាពលរដ្ឋត្រូវបានជម្លៀសចេញពីរដ្ឋធានីអស់រលីង។ រដ្ឋបាលខ្មែរក្រហមមាននៅទីក្រុងភ្នំពេញ ប៉ុន្តែរយៈពេលបួនឆ្នាំ រាល់ការបំពាក់បរិក្ខារសំដៅទៅផ្គត់ផ្គង់ទឹកស្អាតមិនបានដំណើរការឡើយ ហើយជាលទ្ធផល ការខូចខាតមានសភាពកាន់តែធ្ងន់ធ្ងរឡើង។ របបខ្មែរក្រហមត្រូវបានបណ្តេញចេញពីទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៩ ហើយប្រជាពលរដ្ឋបានចាប់ផ្តើមត្រឡប់មកទីក្រុងភ្នំពេញវិញ។ ស្ថានីយផលិតទឹកស្អាតដែលត្រូវបានគេបោះបង់ចោលក៏ចាប់ផ្តើមដំណើរការឡើងវិញ ប៉ុន្តែតាមរបៀបមួយដែលមិនទាន់បានរៀបចំស្រួលបួលនៅឡើយទេ។

នៅឆ្នាំ១៩៩២ ស្ថានភាពនៅតែស្មុគស្មាញនៅឡើយសម្រាប់ប្រជាពលរដ្ឋគ្រប់រូបនៅទីក្រុងភ្នំពេញ។ មួយភាគធំនៃប្រព័ន្ធទឹកស្អាតមិនអាចប្រើប្រាស់បានឡើយ។ រដ្ឋាករទឹកភ្នំពេញអាចផលិតទឹកបានប្រមាណជា ៦៥០០០ ម៉ែត្រគូបប៉ុណ្ណោះ ពោលគឺស្មើនឹងប្រមាណជា ៤០%នៃសមត្ថភាពផលិតទាំងមូល។ បរិមាណនោះអាចផ្គត់ផ្គង់ជូនប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញបានប្រមាណជា ២៥%ប៉ុណ្ណោះ។ មានទឹកតែមួយផ្នែកប៉ុណ្ណោះដែលត្រូវបានចែកចាយដល់គ្រួសារប្រជាពលរដ្ឋរហូតដល់អគារ តាមរយៈបណ្តាញចែកចាយប្រវែង ២៨៨ គីឡូម៉ែត្រ។ ជាការពិត ប្រជាពលរដ្ឋដែលត្រឡប់មកក្នុងទីក្រុងវិញ បូមទឹកមួយផ្នែ កពីអណ្តូងចំនួន១៩៤ ៥ កន្លែង ជាអណ្តូងដែលពួកគេបានជីកដោយខ្លួនឯង[1]។ ការជីកអណ្តូងទាំងនេះធ្វើឱ្យដាច់ទុយោទឹកនៃខ្សែបណ្តាញចែកចាយដែលកប់ក្រោមដី។ ប្រជាពលរដ្ឋបានដាក់ម៉ូទ័របូមទឹកចេញពីអណ្តូងទាំងនេះ។ គេបានតទុយោចេញពីអណ្តូងកាត់តាមប្រលោះបង្ហូចដើម្បីបញ្ជូនទឹកទៅក្នុងផ្ទះ។ ទុយោដែលគេតប្រទាក់ក្រឡាគ្នានេះ គេឱ្យឈ្មោះនៅពេលនោះថាខ្ទាត់ខ្ទែងដូចសំបុកពីងពាង។ ប្រជាពលរដ្ឋដោះស្រាយដោយតទុយោតាមរបៀបនេះនៅក្នុងទសវត្សរ៍ឆ្នាំ៨០ មិនអនុញ្ញាតឱ្យបណ្តាញរដ្ឋាករទឹកដំណើរការល្អទេ ពីព្រោះបន្ថែមពីលើអណ្តូងដែលមានចំនួនច្រើនហើយនោះ នៅមានការបាត់បង់ទឹកផ្សេងទៀត ធ្វើឱ្យសំពាធទឹកនៅក្នុងបណ្តាញទាំងមូលចុះខ្សោយខ្លាំង។ វាធ្វើឱ្យ ការបញ្ជូនទឹកទៅតាមផ្ទះដែលបានតទឹកត្រឹមត្រូវមិនអាចទៅរួចឡើយ។ លើស ពីនោះទៀត សេវាចែកចាយទឹករដ្ឋអាចប្រមូលការបង់ប្រាក់បានតែ៤៨% នៃទឹកដែលបានផលិតឡើងប៉ុណ្ណោះ ដោយសារបញ្ហីអតិថិជនខុស ឬក៏ចាស់ពេកដោយសារការប្រើប្រាស់គ្មានការវាស់វែង អ្នកខ្លះគ្មានចេតនាបង់វិក្ក័យបត្រ និង ដោយសារអំពើពុករលួយ ប្រព្រឹត្តដោយអ្នកដែលទៅប្រមូលលុយ។ មានតែប្រមាណ២៥%នៃទឹកផលិតបានប៉ុណ្ណោះដែលផ្តល់ជាចំណូលប្រមូលបានពិតប្រាកដ។ ហេតុនេះហើយបានជាសេវារដ្ឋគ្មានលទ្ធភាពផ្តល់ប្រាក់ខែឱ្យបានសមរម្យជូនមន្ត្រីរបស់ខ្លួន។ ប្រាក់ខែសម័យនោះបានត្រឹមតែ ១ដុល្លារប៉ុណ្ណោះក្នុងមួយថ្ងៃ។ ដោយសាររដ្ឋាករទឹកមិនដែលមានលទ្ធភាពបង់វិក្ក័យបត្រភ្លើងសម្រាប់ធ្វើឱ្យរោងចក្រផលិតទឹកស្អាតដំណើរការនោះ ទើបរដ្ឋាករប្រកាសក្សោយធន។

នៅឆ្នាំ១៩៩៣ ស្ថានភាពអំណោយផល យើងអាចចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់បាន។ បន្ទាប់ពីបានបោះឆ្នោតតំណាងរាស្ត្រ នៅខែកក្កដា ឆ្នាំ១៩៩៣ ដែលមានការជួយជ្រោមជ្រែងពីអង្គការសហប្រជាជាតិ រដ្ឋាភិបាលជាប់ឆ្នោតបានអនុម័តលើយុទ្ធសាស្ត្រសេដ្ឋកិច្ចទីផ្សារសេរីមួយ ហើយសេវាផ្គត់ផ្គង់ទឹកស្អាតក៏អាចរៀបចំឡើងវិញបានដោយប្រើជំរាជំនួយអន្តរជាតិ។ សេវាសាធារណៈ:ពេលនោះបានទទួលជំនួយពីអង្គការ UNDP ពីប្រទេសបារាំង និងប្រទេសជប៉ុន ដើម្បីពង្រឹងសមត្ថភាពស្ថាប័នរបស់ខ្លួន និងអនុវត្តគម្រោងបន្ទាន់នានា។ ខ្ញុំបានទទួលបន្ទុកដឹកនាំរដ្ឋាករទឹក នៅថ្ងៃ១១ ខែកញ្ញា ឆ្នាំ១៩៩៣។ ដើម្បីប្រឈមមុខនឹងស្ថានភាពធ្ងន់ធ្ងរដែលបានលើកឡើងខាងលើ ខ្ញុំបានបង្កើតក្រុមការងារមួយដែលមានបុគ្គលិកវ័យក្មេង សកម្ម ចេះដឹង និងមានចិត្តចង់ធ្វើការខ្លាំង។ នៅក្នុងដំណាក់កាលដំបូង យើងបានផ្តោតលើសកម្មភាពការងារសំខាន់ៗចំនួនបី ដែលជាស្នូលនៃផែនការជម្រុញឡើងវិញ៖ (១). ការផ្លាស់ប្តូរទម្លាប់ (២). ប្រសិទ្ធភាពប្រតិបត្តិការ និង (៣). ការអភិវឌ្ឍប្រកបដោយចីរភាព។ ដើម្បីផ្លាស់ប្តូរទម្លាប់ យើងបានប្រកាន់យកពាក្យស្លោកនៃជនក្លាហានទាំងបីរូបគឺ “ម្នាក់ដើម្បីគ្រប់គ្នា គ្រប់គ្នាដើម្បីម្នាក់”។ យើងក៏បានដើរតាមគោលការណ៍នេះដែរគឺ “ប្រជានត្រូវផ្តល់គម្រូ”។ ដើម្បីផ្លាស់ប្តូរគំនិត និងធ្វើឱ្យបុគ្គលិកកាន់តែមានទឹកចិត្ត យើងបានបណ្តុះណ្តាលមេក្រុម និងផ្តល់ប្រាក់កម្រៃសមរម្យ ដាក់ចេញនូវវិធានការលើកទឹកចិត្ត និងមានវិន័យម៉ឹងម៉ាត់ ព្រមទាំងមានការដាក់ពិន័យតឹងតែងទៀតផង។ ដើម្បីអាចផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋយើងក្នុងតម្លៃសមរម្យ យើងដឹងថា យើងត្រូវតែធ្វើការឱ្យមានប្រសិទ្ធភាពក្នុងគ្រប់ប្រតិបត្តិការ។ យើងបានផ្តោតជាពិសេសទៅលើការសន្សំសំចៃ និងកាត់បន្ថយការបាត់បង់ទឹក ជាពិសេសគឺការបាត់បង់ចំណូលដោយខំលុបបំបាត់ការតទឹកខុសច្បាប់។ ដើម្បីឱ្យអ្នកប្រើប្រាស់បង់វិក្ក័យបត្រ

Photographie des familles au moment du raccordement (PPWSA).

Photographs of the families on completion of the connection (PPWSA).

ពិតប្រាកដ យើងបានធ្វើបច្ចុប្បន្នភាពជាបន្ទាន់នូវបញ្ជីអ្នកជាវ ដោយចុះរាប់ការតទឹកនីមួយៗ និងយកទិន្នន័យមកដាក់ក្នុងប្រព័ន្ធពត៌មានវិទ្យា ដើម្បីចេញវិក្ក័យបត្រចាប់តាំងពីឆ្នាំ១៩៩៣មក ដោយមានជំនួយបារាំង។

បីឆ្នាំបន្ទាប់ពីកំណែទម្រង់របស់យើងមក ស្ថានភាពបានចាប់ផ្តើមប្រសើរឡើង។ បុគ្គលិកចាប់ផ្តើមមានទឹកចិត្តធ្វើការដើម្បីបម្រើប្រយោជន៍រួម។ ផលិតកម្មបានកើនឡើង ការបាត់បង់ទឹកក៏ថយចុះ ហើយប្រាក់ចំណូលទទួលបានគ្រប់គ្រាន់ដើម្បីធានាលើចំណាយសំខាន់ៗ ដោយផ្តល់ប្រាក់ខែសមរម្យជូនបុគ្គលិក។ នៅឆ្នាំ១៩៩៧ រដ្ឋាភិបាលបានចេញច្បាប់មួយ ផ្តល់ស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុដល់រដ្ឋាករទឹក។ ពេលនោះ រដ្ឋាករទឹកក៏បានផ្លាស់ឈ្មោះមកជា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ជាភាសាអង់គ្លេសថា PPWSA។ ដោយសារពេលនោះទឹកមានតម្លៃតែ២៥០រៀលក្នុងមួយម៉ែត្រគូប សម្រាប់អ្នកប្រើប្រាស់តាមផ្ទះ និង៧០០រៀលក្នុងមួយម៉ែត្រគូបសម្រាប់អ្នករកស៊ី តម្លៃនោះពិតជាទាបខ្លាំងណាស់ បើប្រៀបធៀបនឹងតម្លៃផលិតកម្ម ដូច្នោះ រដ្ឋាភិបាលបាន អនុញ្ញាតឱ្យរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញពិនិត្យតម្លៃឡើងវិញ។ នៅខែមករា ឆ្នាំ១៩៩៧ តម្លៃទូទៅសម្រាប់គ្រួសារក្រីក្រត្រូវបានសម្រេច បន្ទាប់មកធ្វើបច្ចុប្បន្នភាពឡើងវិញនៅខែមករា ឆ្នាំ២០០១។ យើងតែងតែគិតថា តម្លៃត្រូវតែឆ្លុះបញ្ចាំងទាំងចំណូល ទាំងប្រសិទ្ធភាពការងាររបស់ក្រុមហ៊ុន ដោយត្រូវរក្សាតម្លៃឱ្យបានសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់រូប។

នៅក្នុងសម័យថ្មីនេះ ដោយមានជំនួយពីបារាំង ជប៉ុន ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក យើងបានចាប់ផ្តើមពង្រីកសមត្ថភាពប្រតិបត្តិការរបស់យើងនៅក្នុងសង្វាក់ផលិតកម្ម ចែកចាយ និងការតខ្សែរបណ្តាញជូនអតិថិជន។ ទន្ទឹមនឹងនោះ យើងក៏បន្តខិតខំធ្វើឱ្យប្រតិបត្តិការកាន់តែមានប្រសិទ្ធភាពជាងមុនដែរ។ ក្នុងរយៈពេល១៨ឆ្នាំ យើងបានកាត់បន្ថយដោយជោគជ័យនូវការបាត់បង់ទឹក ពី ៧២% នៅឆ្នាំ១៩៩៣ មកត្រឹម ៥,៩% នៅឆ្នាំ២០១២។ ក្នុងរយៈពេលដដែលនោះ មូលដ្ឋានទិន្នន័យនៃអ្នកជាវ គឺបានឈានពី ២៦៨៨១ តំណ ទៅដល់ ២២ម៉ឺនតំណ ហើយខ្សែរបណ្តាញចែកចាយទឹកពីបានកើនឡើងពីប្រវែង ២៨៨គីឡូម៉ែត្រ ទៅ ២ពាន់គីឡូម៉ែត្រ។ ដូចគ្នាដែរ ផ្ទៃដីចែកចាយទឹកគឺបានប្តូរពី ២០% ទៅ៩០% ហើយអត្រានៃការប្រមូលចំណូលមកវិញបានឈានដល់ ៩៩,៩%។ សំខាន់ជាងនេះទៅទៀតនោះគឺបុគ្គលិករបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានទទួលប្រាក់ខែខ្ពស់ជាងមន្ត្រីរាជការផ្សេងទៀត។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានធានាប្រកបដោយជោគជ័យនូវនិរន្តរភាពនៃលទ្ធផលទាំងនេះ។

ទោះបីជាយើងបានពង្រីកផ្ទៃដីសេវាកម្មយ៉ាងណាក្តី ក៏យើងមិនដែលបោះបង់ចោលប្រជាពលរដ្ឋក្រីក្រឡើយ។ កាលពីមុន ប្រជាពលរដ្ឋក្រីក្រមិនដែលមានសំណាងទទួលបានទឹកស្អាតប្រើប្រាស់នៅក្នុងទីក្រុងទេ។ ដោយសារគ្មានការតទឹកទៅនឹងបណ្តាញទឹករដ្ឋ ប្រជាពលរដ្ឋក្រីក្រចំណាយលើទឹកថ្លៃជាងប្រជាពលរដ្ឋផ្សេងទៀត ពីព្រោះពួកគាត់ត្រូវតែទិញទឹកពីឈ្មួញកណ្តាល។ ចាប់ពីឆ្នាំ១៩៩៩មក ដោយមានជំនួយពីប្រទេសផ្តល់ជំនួយ ជាពិសេសគឺប្រទេសបារាំង តាមរយៈមូលនិធិទឹក (ផ្តល់តាមរយៈភ្នាក់ងារទឹកបារាំង) និងសាលាក្រុងប៉ារីស រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានចុះតម្លៃ២០%ទៅលើចំណាយតទឹកសម្រាប់ជនក្រីក្រ និងការបង់ប្រាក់អាចធ្វើទៅបានក្នុងរយៈពេល២០ខែ។ នៅឆ្នាំ២០០៣ ដោយសារលទ្ធផលហិរញ្ញវត្ថុវិជ្ជមាន និងដោយមានជំនួយពីមូលនិធិទីបារាំង យើងក៏បានអនុវត្តកម្មវិធីថ្មីមួយទៀត ដែលមាន ឈ្មោះថា “ទឹកសម្រាប់ទាំងអស់គ្នា”។ គម្រោងនោះជួយលើចំណាយនៃការតទឹករហូតដល់ ៣០%, ៥០%, ៧០% ឬ១០០% ដោយផ្អែកលើលក្ខខណ្ឌវាយតម្លៃសង្គម ធ្វើឡើងដោយគណៈកម្មាធិការចម្រុះមួយ។ តម្លៃទឹករបស់យើងត្រូវបានកាត់បន្ថយ ដោយសារយើងបញ្ចុះតម្លៃដោយប្រើប្រាក់ចំណេញ។ ជាលទ្ធផល សហគមន៍ប្រជាពលរដ្ឋជាង១០០សហគមន៍នៅទីក្រុងភ្នំពេញទទួលបានទឹកស្អាតដោយផ្ទាល់ពីខ្សែបណ្តាញរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ នៅឆ្នាំ២០១១ ជាង៧០%នៃតំណចំនួន២១ ៤៩០ ដែលត្រូវបានធ្វើឡើង គឺជាតំណដែលយើងហៅថាតំណសង្គម ពីព្រោះការតទឹកទាំងនោះ គឺភាគច្រើនជារបស់គ្រួសារជនក្រីក្រ ដែលគ្មានមធ្យោបាយ ដូច្នេះគឺពួកគេទទួលបានការឧបត្ថម្ភទាំងស្រុង។ គោលនយោបាយនេះបានផ្តល់ផលជះយ៉ាងសំខាន់ទៅលើសុខភាព និងសុខមាលភាពរបស់ប្រជាពលរដ្ឋតាមគ្រួសារ ជាអាទ៍គឺទៅលើការកាត់បន្ថយជម្ងឺឆ្លង បង្ករឡើងដោយទឹក។ គោលនយោបាយនេះក៏អនុញ្ញាតផងដែរ ឱ្យស្ត្រីនិងកុមាររាប់ពាន់នាក់ ដកបន្ទុកដ៏ធ្ងន់ចេញពីលើស្មា ក្នុងការស្វែងរកទឹកប្រចាំថ្ងៃ។ ចុងបញ្ចប់ ខ្ញុំសូមធ្វើការសន្និដ្ឋានដោយនិយាយថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានចាប់កំណើតឡើងពីស្ថានភាពមួយយ៉ាងលំបាកលំបិនបំផុត ខណៈនោះ២០%តែប៉ុណ្ណោះនៃគ្រួសារប្រជាពលរដ្ឋអាចទទួលបានទឹកប្រើប្រាស់ ហើយការទទួលនោះទៀតសោតក៏មិនជាប់លាប់ទៅទៀត។ បច្ចុប្បន្ននេះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានក្លាយជាសេវាផ្គត់ផ្គង់ទឹកស្អាតដែលមានគុណវុឌ្ឍិខ្លាំងមួយនៅក្នុងតំបន់។

សមិទ្ធផលដែលយើងអាចសម្រេចបាន គឺដោយសារហេតុផលបីសំខាន់ៗ៖ (ក). ស្ថិរភាពសង្គម និងចេតនានយោបាយរបស់រដ្ឋាភិបាល (ខ). ជំនួយ ពីដៃគូអភិវឌ្ឍន៍និង (គ). អភិបាលកិច្ចល្អ “សមធម៌សម្រាប់មនុស្ស គ្រប់រូប ម្ចឹងម៉ាត់ចំពោះគោលដៅ និងជឿជាក់ចំពោះថ្នាក់ដឹកនាំ និងអ្នកទទួលបានការ ឧបត្ថម្ភ” ដែលអនុវត្តដោយក្រុមការងារមួយ ដែលមានការប្តេជ្ញាខ្ពស់ មានផ្នត់គំនិតជាសហគ្រិនខ្លាំង និងដាក់ចិត្តដាក់កាយបម្រើសេវាសាធារណៈ។

1 ជាតួលេខដែលយើងបានធ្វើស្ថិតិនៅដើមអាណត្តិរបស់ខ្ញុំ។

Regard sur la reconstruction de la ville de Kigali

Kigali, capitale du Rwanda, a relevé de nombreux défis depuis le génocide de 1994. En un peu plus de 25 ans, elle est devenue l'une des capitales les plus dynamiques du continent africain. **PAR NADINE UMUTONI GATSINZI**

Kigali, fondée en 1907 en tant que petit avant-poste colonial ayant peu de liens avec le monde extérieur, a maintenant plus de 100 ans. Peuplée de plus de 1,6 million d'habitants, la Ville de Kigali est aujourd'hui, non seulement la capitale nationale, mais aussi le principal centre d'affaires et commercial du pays. La métropole rwandaise est aussi l'une des capitales africaines les plus propres et les plus sûres, et les projections indiquent que sa population pourrait atteindre 5 millions d'habitants en 2050.

1994, UN PAYS DÉVASTÉ

Toutefois, il y a 25 ans, juste après l'arrêt du Génocide contre les Tutsi et la libération du Rwanda par le Front Patriotique Rwandais le 04 Juillet 1994, le Rwanda était qualifié d'État défaillant. Son capital humain était dévasté, avec plus d'un million de vies perdues, environ 3 millions de réfugiés et des centaines de milliers de personnes emprisonnées, soupçonnées d'avoir commis un génocide contre les Tutsi. L'économie rwandaise a diminué de 50% en 1994. Le PIB par habitant est tombé à 146 dollars, l'inflation était à 64% et la pauvreté atteignait 78%. La fonction publique était caractérisée par un personnel à très faible capacité, avec plus de 80% sans qualification d'enseignement supérieur.

RECONSTRUIRE LA SOCIÉTÉ PAR UNE BONNE GOUVERNANCE ET DES POLITIQUES DE DÉVELOPPEMENT

រូបភាពប៉ាណូរ៉ាមិកចាប់ពីតីរវិចីព្រះស៊ីសុវត្ថិ ទៅជ្រោយចង្វារ ឆ្នាំ២០១៩

បញ្ហាប្រឈមបច្ចុប្បន្នក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ

ជារាជធានីមានភាពធន់ ភ្នំពេញកំពុងសម្លឹងមើលទៅអនាគត។ រដ្ឋបាលសាលារាជធានីភ្នំពេញនៅតែបន្តស្វែងរកមធ្យោបាយថ្មីៗ និងប្រកបដោយនវានុវត្តន៍ ដើម្បីជម្រុញការអភិវឌ្ឍក្រុង ហើយកំណើនខ្លាំងនិងលឿនត្រូវតែឆ្លើយតបទៅនឹងបញ្ហាប្រឈមថ្មីៗ។ ដោយលោក សេង រណ្ណ:

សម្ទុះនិងកំណើនប្រជាសាស្ត្រយ៉ាងលឿន

បច្ចុប្បន្ននេះ រាជធានីភ្នំពេញគឺជាចលការសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងដែនដីទីក្រុងភ្នំពេញទាំងមូល មានរោងជាងសិប្បកម្ម៣៨៤០កន្លែង និងរោងចក្រ៨៥៧កន្លែង ភាគច្រើនជារោងចក្រកាត់ដេរ។ ប្រជាពលរដ្ឋក្នុងទីក្រុងភ្នំពេញមានចំនួនកើនឡើងយ៉ាងលឿន ជិត៤%ក្នុងមួយឆ្នាំៗ។ បន្ថែមពីលើប្រជាពលរដ្ឋដែលរស់នៅជាប់ជាប្រចាំជាង២លាននាក់ នៅមានប្រមាណជា១លាននាក់បន្ថែមទៀតឆ្លងកាត់ប្រចាំថ្ងៃ។ តាំងពីឆ្នាំ១៩៧៩មក ផ្ទៃដីទីក្រុងភ្នំពេញបានកើនឡើងគុណនឹងបួនដង។

ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបណ្តាលមកពីកំណើនចំនួនប្រជាពលរដ្ឋយ៉ាងខ្លាំងនេះ សាលារាជធានីភ្នំពេញបានបង្កើតនិងអនុវត្តគម្រោងរៀបចំដែនដីជាច្រើនគម្រោង។ ផ្ទៃដីរាជធានីបានរីកធំ ហើយខណ្ឌថ្មីៗត្រូវបានបង្កើតឡើង៖ បច្ចុប្បន្ននេះ មានខណ្ឌទាំងអស់ចំនួន១៤ ពោលគឺមានខណ្ឌចំនួន៥បន្ថែមទៀត បើប្រៀបធៀបនឹងកាលពីជាង១០ឆ្នាំមុន។ ម្យ៉ាងវិញទៀតរបៀបទាក់ទងគ្នា រវាងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ក៏កាន់តែប្រសើរជាងមុនដែរ។ របៀបទាក់ទងល្អនេះ អនុញ្ញាតឲ្យយើងឆ្លើយតបបានកាន់តែលឿននិងប្រសើរ ដល់ក្តីរំពឹងផ្ទាល់របស់ខណ្ឌនីមួយៗ។ ប្លង់មេរហូតដល់ឆ្នាំ២០៣៥ គឺជាឧបករណ៍មួយទៀត ដែលយើងបានបង្កើតឡើង ហើយដែលអាជ្ញាធរសាធារណ:អាចប្រើដើម្បីដោះស្រាយបញ្ហាអភិវឌ្ឍន៍ក្រុង។ ដើម្បីជួយសម្រួលឲ្យប្រជាពលរដ្ឋងាយទទួលបាននូវសេវារដ្ឋបាលមូលដ្ឋាន (លិខិតស្នាមអត្រានុកូលដ្ឋាន អាជ្ញាប័ណ្ណ បើកមុខរបររកស៊ីផ្សេងៗ។ល។) ការបង្កើតប្រព័ន្ធប្រកចេញចូលតែមួយ នៅឆ្នាំ២០១៦ បានអនុញ្ញាត តាំងពីពេលនោះមក ឲ្យប្រជាពលរដ្ឋដោះស្រាយបញ្ហាលិខិតស្នាមរដ្ឋបាលតាមរបៀបមួយដែលសាមញ្ញ និងមានតម្លាភាពដោយសារតែយើងមានប្រព័ន្ធប្រកចេញចូលនិងតម្លៃតែមួយសម្រាប់គ្រប់ប្រភេទនៃឯកសារទាំងអស់។

ទីក្រុងរីកធំឥតឈប់

ដោយសារប្រជាពលរដ្ឋមានចំនួនកើនឡើង ទីក្រុងក៏កាន់តែរីកធំទៅៗទាំងទៅខាងលើ ទាំងផ្ទៃខាងក្រោម។ ទេសភាពក្រុងវិវឌ្ឍទៅមុខយ៉ាងលឿន។ ៤០%នៃអគារសាងសង់បច្ចុប្បន្ននេះមានកម្ពស់លើសពី១០ជាន់ (៣១៧អគារក្នុងចំណោម៧៩១អគារ) ខណ:ដែលភ្នំពេញគ្មានអគារខ្ពស់មួយឡើយកាលពី ១៥ឆ្នាំមុន។ អគារខ្ពស់លើកដំបូងត្រូវបានសង់ចប់រួចរាល់នៅឆ្នាំ២០១០។

យើងឃើញមានរបៀបរស់នៅថ្មីក្នុងទីក្រុង។ សំណង់បុរីបានរីកច្រើនដូចផ្សិត។ នៅក្នុងបុរីតូចធំទាំងនេះ មានផ្ទះវីឡាទោល វីឡាភ្លោះ ផ្ទះល្វែងសម្រាប់ប្រជាពលរដ្ឋរស់នៅ និងមានរបងព័ទ្ធជុំវិញបុរី មានសេវាមូលដ្ឋាន ដូចជា ផ្សារសាលារៀន ហើយពេលខ្លះ មានតែម្ចាស់ផ្ទះនៅក្នុងបុរីប៉ុណ្ណោះដែលមានសិទ្ធិចេញចូលបាន។ បច្ចុប្បន្ននេះ ទីក្រុងភ្នំពេញមានសំណង់បុរី ១៣៤កន្លែងជាពិសេស គឺនៅតាមតំបន់ជាយក្រុង។ ម្យ៉ាងវិញទៀត មានការអភិវឌ្ឍទីក្រុងរណបមួយចំនួននៅជាយរាជធានីផងដែរ។ ថ្វីត្បិតថា សំណង់បុរីថ្មីៗទាំងនេះបង្កើតលំហសម្រាប់គេហដ្ឋានរស់នៅតាមបែបថ្មីមួយ ប៉ុន្តែសមាហរណកម្មបុរីទៅក្នុងទីក្រុងពិតជាមានភាពស្មុគស្មាញក្នុងការគ្រប់គ្រង បើនិយាយពីចរាចរណ៍ និងការភ្ជាប់បុរីទៅទីក្រុងចាស់។ បញ្ហាមួយទៀងនោះ គឺគេហាមឃាត់មួយភាគនៃប្រជាពលរដ្ឋមិនឲ្យចូលទៅក្នុងទីតាំងមួយចំនួនក្នុងបុរីឡើយ។ នៅក្នុងបរិបទនេះ កម្មវិធីសហប្រតិបត្តិការរវាងស្ថាប័ន APUR (អង្គភាពនគរូបនីយកម្មក្រុងប៉ារីស) និងសាលារាជធានីភ្នំពេញ ចាប់តាំងពីឆ្នាំ២០១៦មក បានជួយប្រឹក្សាដល់គម្រោង ING City នៅក្នុងការអភិវឌ្ឍតំបន់មួយដែលមានផ្ទៃដី២៥០០ហិចតា នៅប៉ែកខាងត្បូងទីក្រុង ម្ពុំបឹងជើងឯក។ គោលការណ៍រៀបចំក្រុងមួយសម្រាប់ធានាឲ្យមានសមាហរណ កម្មល្អនៃគម្រោងទាំងនេះទៅក្នុងការអភិវឌ្ឍក្រុងត្រូវបានដាក់ចេញ។ អនុសាសន៍ទាំងនេះផ្តោតជាអាទិ៍ទៅលើសារ:សំខាន់នៃទីតាំងសាធារណ: ការរក្សាផ្ទៃបឹងមួយផ្នែក លូនៅក្នុងដីរដ្ឋ និងទីតាំងសម្រាប់ការប្រើប្រាស់រួម ព្រមទាំង

សមាហរណកម្មសង្គាត់ប្រជាពលរដ្ឋក្រីក្រនៅក្នុងតំបន់អភិវឌ្ឍន៍ថ្មីនោះ និងការគិតគូរពីភូមិទាំងឡាយដែលមានស្រាប់ក្នុងតំបន់នៃគម្រោង។

ម្យ៉ាងវិញទៀត សាលារាជធានីភ្នំពេញក៏ធ្វើការផងដែរលើសមាហរណកម្មនៃប្រជាពលរដ្ឋក្រីក្រជាងគេនៅក្នុងទីក្រុង។ គម្រោងដែលយើងទើបចាប់ផ្តើមអនុវត្តនៅឆ្នាំនេះ ដោយសហការដៃគូជាមួយសមាគម AIMF (សមាគមអន្តរជាតិនៃអភិបាលក្រុងនិយាយភាសាបារាំង) និងសមាគមអ្នកតំណាងនៅតាមមូលដ្ឋានក្នុងប្រទេសកម្ពុជា សំដៅជាអាទ៍ទៅធ្វើសមាហរណកម្មចូលក្នុងសង្គាត់ដែលមានការរៀបចំថ្មី នូវប្រជាពលរដ្ឋ ដែលបច្ចុប្បន្ននេះរស់នៅក្នុងផ្ទះសម្បែងមិនសូវមាំទាំ តាមបណ្តោយលូស្ទឹងមានជ័យ នៅប៉ែកខាងត្បូងធៀងខាងកើតនៃរាជធានី។

ដោយសារសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋានមានការកើនឡើង និងមានការផ្តល់ជាជំនួយបច្ចេកទេសពីសាលារាជធានីភ្នំពេញ លក្ខខណ្ឌស្ថាបត្យកម្មអប្បរមាមួយនៃសំណង់ថ្មីៗទាំងនេះត្រូវបានដាក់ចេញ ហើយការរៀបចំទីតាំងសាធារណៈត្រូវបានធ្វើឡើង ដើម្បីជានាថា សង្គាត់ទាំងនេះមានលក្ខណៈដូចសង្គាត់ផ្សេងទៀតដែរ នោះគឺដើម្បីឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុងសង្គាត់ថ្មីៗទាំងនេះមានអារម្មណ៍ថា ពួកគាត់ក៏ដូចប្រជាពលរដ្ឋក្នុងសង្គាត់ផ្សេងទៀតដែរ ដោយទទួលបាននូវក្របខណ្ឌនៃការរស់នៅមួយសមរម្យ ព្រមទាំងទទួលបានការគិតគូរដូចប្រជាពលរដ្ឋផ្សេងទៀតនៅក្នុងរាជធានីភ្នំពេញដែរ។

បញ្ហាប្រឈមចំនួន៣ សម្រាប់អនាគត

ភ្នំពេញនឹងត្រូវដោះស្រាយបញ្ហាប្រឈមធំៗចំនួន៣ នៅក្នុងទសវត្សរ៍ខាងមុខនេះហើយសុទ្ធតែជាបញ្ហាប្រឈមជុំវិញប្រធានបទធំមួយ គឺនិរន្តរភាពនៃការអភិវឌ្ឍក្រុង។

គ្រប់គ្រងការប្រើប្រាស់ថាមពលនៅក្នុងទីក្រុង

នៅក្នុងរដូវប្រាំងកន្លងទៅនេះ សីតុណ្ហភាពនៅក្នុងទីក្រុងបានកើនឡើងយ៉ាងខ្លាំង និងបណ្តាលឲ្យមានភាពរាំងស្ងួតមួយយ៉ាងធំ ដូចនៅគ្រប់ទីកន្លែងផ្សេងទៀតលើភពផែនដីដែរ។ ភាគច្រើននៃថាមពលប្រើប្រាស់ក្នុងទីក្រុងពឹងផ្អែកទៅលើរោងចក្រវារីអគ្គិសនីនៅតាមដងទន្លេមេគង្គ ខណៈដែលកម្រិតទឹកទន្លេកាលពីឆ្នាំកន្លងទៅនេះ ទាបយ៉ាងខ្លាំង មិនធ្លាប់មានពីមុនមក។ នៅក្នុងរាជធានីទាំងមូល ក្នុងរយៈពេលជិត៣សប្តាហ៍ ភ្លើងបានដាច់រៀងរាល់ថ្ងៃ ពី៣ ទៅ៨ម៉ោងដែលធ្វើឲ្យប៉ះពាល់ដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងទៅលើសេដ្ឋកិច្ច។ បាតុភូតធ្ងន់ធ្ងរបែបនេះ នាំឲ្យយើងលើកជាសំណួរច្រើនអំពីភាពធន់នៃរាជធានីភ្នំពេញចំពោះបម្រែបម្រួលអាកាសធាតុ។ ពិតមែនហើយ សំណួរគឺថា តើត្រូវធ្វើយ៉ាងណាដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពលក្នុងទីក្រុង ដើម្បីជានាឲ្យទីក្រុងមានស្វ័យភាពខាងផ្នែកថាមពល ទោះបីជាមួយផ្នែកក៏ដោយនោះ ? តើត្រូវធ្វើបែបណាដើម្បីកាត់បន្ថយកំដៅនៅក្នុងតំបន់ក្រុង និងរក្សាសីតុណ្ហភាពធម្មជាតិដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចរស់នៅបាន ?

ទីក្រុងភ្នំពេញបានចាប់ផ្តើមពិចារណាទៅលើសំណួរទាំងនេះហើយ។ ជាអាទ៍ យើងបានធ្វើការជាមួយក្រុង Kitakyūshū របស់ជប៉ុន ដែលចងសម្ព័ន្ធមេត្រីភាពជាមួយទីក្រុងភ្នំពេញ ព្រមទាំងជាមួយអង្គការ GGGI (វិទ្យាស្ថានកំណើនបៃតងពិភពលោក)។ ភាពជាដៃគូទាំងនេះ បានអនុញ្ញាតឲ្យយើងបង្កើតយុទ្ធសាស្ត្រទីក្រុងបៃតង ព្រមទាំងបង្កើតយុទ្ធសាស្ត្រក្រុងដើម្បីប្រែក្លាយរាជធានីភ្នំពេញ ឲ្យក្លាយជាទីក្រុងមួយមាននិរន្តរភាព។ លំហបៃតងគឺជាអ្វីដែលទីក្រុងភ្នំពេញខិតខំកសាងអស់រយៈពេលជាងមួយទសវត្សរ៍កន្លងមកហើយ ដោយបង្កើតសួន និងឧទ្យានសាធារណៈនៅក្នុងទីក្រុង ឧទាហរណ៍ ដូចជាការជួសជុលឧទ្យានវត្តភ្នំជាដើម។ គម្រោងជាច្រើនផ្សេងទៀតអាចនឹងលេចចេញជារូបរាងឡើង ដើម្បីអនុញ្ញាតឲ្យទីក្រុងភ្នំពេញលើកសំណើដំណោះស្រាយជាក់ស្តែង។

ជាទ្រង់ទ្រាយធំទៅថ្ងៃអនាគត កិច្ចការដែលយើងត្រូវធ្វើ គឺយើងនឹងបង្កើតទីតាំងសាធារណៈឲ្យបានច្រើន ដើម្បីជាប្រយោជន៍របស់ប្រជាពលរដ្ឋ និងជម្រុញពួកគាត់ឲ្យចូលរួមកាន់តែច្រើនថែមទៀតនៅក្នុងជីវិតរស់នៅក្នុងទីក្រុង។ ទីកន្លែងនិងសួនសាធារណៈបច្ចុប្បន្ននេះ ត្រូវបានប្រជាពលរដ្ឋប្រើប្រាស់ដើម្បីធ្វើលំហាត់ប្រាណ និងដើរកំសាន្ត ដូច្នេះតាមរបៀបនេះ ប្រជាពលរដ្ឋពិតជាចូលរួមក្នុងការកសាង ក៏ដូចជាការសាងឡើងវិញនូវអារម្មណ៍ថា ភ្នំពេញជាទីក្រុងរបស់ពួកគាត់ ហើយពួកគាត់នឹងចូលរួមក្នុងការអភិវឌ្ឍអត្តសញ្ញាណប្រជាពលរដ្ឋមួយ។

គ្រប់គ្រងនិងកែលម្អចរាចរណ៍ផ្លូវគោក

ជាធម្មតា ប្រធានបទពាក់ព័ន្ធនឹងលំហសាធារណៈពិតជានាំយើងទៅគិតដល់ការធ្វើយ៉ាងណាឲ្យចរាចរណ៍មានភាពរលូន។ ការធ្វើដំណើរដោយថ្មើជើងនៅក្នុងទីក្រុងបច្ចុប្បន្ននេះ គឺជារឿងលំបាកបំផុត។ ចិញ្ចើមផ្លូវមួយភាគធំត្រូវបានប្រជាពលរដ្ឋដែលរស់នៅជាន់ផ្ទាល់ដីយកទៅប្រើប្រាស់ជាលក្ខណៈឯកជន ដូចជាធ្វើចំណតយានយន្ត ធ្វើជាទីតាំងរកស៊ី ឬជាកន្លែងជួសជុលផ្សេងៗ។ ដូច្នេះ ក្នុងនាមសាលារាជធានីភ្នំពេញយើងត្រូវធ្វើការជាមួយរដ្ឋអំណាចមូលដ្ឋាន និងប្រជាពលរដ្ឋ ដើម្បីយកចិញ្ចើមផ្លូវទាំងនេះមកជូនប្រជាពលរដ្ឋគ្រប់គ្នាប្រើប្រាស់ជាសាធារណៈ: ធ្វើបែបនេះបាន គឺយើងនឹងកែលម្អចរាចរណ៍ថ្មើជើង។ ប៉ុន្តែ យើងប្រឈមមុខនឹងបញ្ហាដែលគ្មានទីបញ្ចប់មួយ នោះគឺប្រជាពលរដ្ឋមិនធ្វើដំណើរថ្មើជើងទេ ដោយសារតែចិញ្ចើមផ្លូវមិនស្រឡះ និងបែរទៅជិះម៉ូតូ ឬជិះរថយន្តវិញ ទោះបីក្នុងចម្ងាយផ្លូវខ្លីក៏ដោយ។

នៅក្នុងទីក្រុងមួយដែលយានយន្តចុះបញ្ជីមានចំនួនរហូតទៅដល់ជាង២លានគ្រឿងទៅហើយនោះ (អត្រាកំណើនមានរហូតដល់១១%ក្នុងមួយឆ្នាំ) បញ្ហាចរាចរណ៍គឺជាក្តីបារម្ភមួយកាន់តែខ្លាំងឡើងសម្រាប់អាជ្ញាធរសាធារណៈ។ ការបង្កើតរដ្ឋាភិបាលស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងនៅឆ្នាំ២០១៨ បានអនុញ្ញាតឲ្យសាលារាជធានីភ្នំពេញដាក់ឲ្យដំណើរការរថយន្តក្រុងចំនួន១៥ខ្សែ ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋគ្រប់រូប ជាពិសេស ប្រជាពលរដ្ឋដែលមានជីវភាពលំបាកជាងគេ។ ជាការពិត កម្មករ កម្មការនី សិស្ស និស្សិត មន្ត្រីរាជការ អាចជិះរថយន្តក្រុងដោយឥតគិតថ្លៃ។ ចំពោះអ្នកត្រង់បង់ថ្លៃ សំបុត្រមានតម្លៃតែមួយគត់ គឺជិះម្តងអស់ថ្លៃ១០០០រៀល។ ទីក្រុងក៏ធ្វើការយ៉ាងសកម្មផងដែរលើការអភិវឌ្ឍនិងកែលម្អខ្សែបណ្តាញផ្លូវថ្នល់របស់ខ្លួន ហើយផ្លូវវាងថ្មីៗជាច្រើនខ្សែនឹងលេចចេញជារូបរាងឡើង ពីពេលនេះដល់ឆ្នាំ២០៣០។

គ្រប់គ្រងកាកសំណល់

បញ្ហាប្រឈមចុងក្រោយដែលសាលារាជធានីភ្នំពេញត្រូវដោះស្រាយ គឺការគ្រប់គ្រងកាកសំណល់។ នៅឆ្នាំ២០១៨ ទីក្រុងបានផលិតសំណល់រឹងចំនួន២៧០០តោនក្នុងមួយថ្ងៃ នេះគឺជាបរិមាណមួយដែលកើនឡើង១៣% ក្នុងមួយឆ្នាំ អស់រយៈពេល១០ឆ្នាំមកហើយ។ កន្លែងចាក់សម្រាមបច្ចុប្បន្ននេះ ដែលយើងបានបើកកាលពី៦ឆ្នាំមុន ត្រូវបានគិតគូរសម្រាប់ចាក់សម្រាមរយៈពេល១០ឆ្នាំ ប៉ុន្តែកន្លែងនេះនឹងត្រូវបិទនៅចុងឆ្នាំនេះ ពីព្រោះសម្រាមពេញទៅហើយ។ ដៃគូជាប្រវត្តិសាស្ត្ររវាងអង្គការ ចៃកា និងសាលារាជធានីភ្នំពេញ លើបញ្ហាលូបង្ហូរទឹក និងការគ្រប់គ្រងទឹកនៅក្នុងទីក្រុង បានអនុញ្ញាតឲ្យយើងបង្កើតគម្រោងសាងសង់ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកកខ្វក់មួយ ហើយការដ្ឋានសាងសង់នឹងចាប់ផ្តើមនៅឆ្នាំក្រោយនេះ។ ចំណុចចុងក្រោយគឺដោយមានការជួយជ្រោមជ្រែងពីសមាគម AIMF សាលាក្រុងបានធ្វើការពិចារណាទៅលើបញ្ហាភាក់បង្គន់ និងទៅលើរបៀបលើកតម្លៃផលិតផលធ្វើចេញពីភាក់បង្គន់នេះនៅនឹងកន្លែង ដូច្នេះគឺអាចជួយជម្រុញឲ្យមានថាមភាពសេដ្ឋកិច្ចមួយផ្នែកក្នុងស្រុក។ គឺនៅក្នុងវិស័យទាំងនេះហើយដែលយើងត្រូវរកឱ្យឃើញនូវដំណោះស្រាយ ប្រកបដោយនវានុវត្តន៍។

សេចក្តីសន្និដ្ឋាន

ភ្នំពេញគឺជាទីក្រុងមួយដែលមានភាពធន់ និងបានរស់រានមានជីវិតឡើងវិញក្រោយឆ្នាំ១៩៧៩ ដោយសារសមត្ថភាពសម្របខ្លួនរបស់ប្រជាពលរដ្ឋ និងសមត្ថភាពរកដំណោះស្រាយតាមបរិបទក្នុងស្រុកផ្ទាល់ ព្រមទាំងដោយសារការធ្វើសមាហរណកម្ម ទម្លាប់ប្រើប្រាស់ និងច្នៃប្រឌិតយន្តការ ដែលគេធ្លាប់អនុវត្ត មានប្រសិទ្ធភាពនៅទីក្រុងផ្សេងទៀតរួចមកហើយ។ សាលារាជធានីភ្នំពេញតែងតែផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការងារជាខ្សែបណ្តាញ ដោយពឹងផ្អែកទៅលើសមត្ថភាពផ្សេងៗជាច្រើន។ ដូច្នេះ សាលារាជធានីបានបើកចំហដល់កិច្ចសហប្រតិបត្តិការមួយយ៉ាងសកម្មជាមួយដៃគូ ដែលជាសង្គមស៊ីវិលដើម្បីរួមគ្នាត្រៀមខ្លួនឲ្យបានកាន់តែប្រសើរសម្រាប់ថ្ងៃអនាគត។ សាលារាជធានីភ្នំពេញសង្ឃឹមយ៉ាងមុតមាំទៅលើការប្តេជ្ញាចូលរួមក្នុងគម្រោងទីក្រុងឆ្លាតវៃ ដែលផ្តួចផ្តើមឡើង និងអភិវឌ្ឍដោយអាស៊ាន ហើយគម្រោងនេះនឹងអនុញ្ញាតឲ្យទីក្រុងភ្នំពេញដោះស្រាយរាល់បញ្ហាទាំងឡាយដូចបានលើកឡើងខាងលើ ដោយបញ្ចូលលទ្ធភាពប្រើបច្ចេកវិទ្យាថ្មីៗ។

Les économies urbaines dynamiques : un vecteur de progrès social dans les villes cambodgiennes

Quel est le premier marqueur du développement d'un pays ? La croissance de ses villes. L'expansion d'une ville, ses infrastructures et la transformation de ses services urbains sont les principaux indicateurs d'une économie croissante, alimentée par les investissements locaux et internationaux.

PAR NATHAROUN NGO

Les économies sont souvent uniquement analysées à l'échelle d'un pays (avec le PIB, la stabilité macroéconomique et fiduciaire, les flux commerciaux, les politiques de migration, etc.). Ce niveau d'analyse a dominé les analyses politiques et économiques dans les quatre dernières décennies. Récemment, dans les cinq à dix dernières années, des travaux d'analyse politique et de recherche académique ont utilisé les villes comme indicateurs mesurant la performance économique. Ce changement peut s'expliquer par la capacité grandissante de récolte et d'analyse de données ventilées au niveau local, combinée avec l'attention croissante portée aux villes. La croissance des taux d'urbanisation à l'échelle mondiale est devenue une force de transformation majeure qui doit être bien gérée par les gouvernements locaux. Ceci est d'autant plus important pour des économies en développement que ce sont dans les villes que cette croissance se concentre. Ceci a un effet direct sur les sources de revenu des habitants tout en déterminant la qualité de leurs conditions de vie.

Au Cambodge, la transformation et la croissance de Phnom Penh dans la dernière décennie sont comparables à celles des pays qui, dans le monde, connaissent la croissance économique la plus rapide. Le concept de villes comme moteur de croissance[1, 2] est maintenant répandu puisque les gouvernements locaux essayent de maximiser les opportunités offertes par la croissance urbaine.

L'intensification du phénomène de départ des usines (à forte intensité de main-d'œuvre) de Chine et d'autres pays asiatiques à cause de salaires plus élevés et la restructuration de chaînes d'approvisionnement régionales ont accéléré l'industrialisation, ce qui a ensuite accéléré le processus d'urbanisation de la région de Phnom Penh. Avec des capacités de fabrication à moindre

coût et une main d'œuvre jeune, le Cambodge est devenu un des lieux de relocalisation privilégié de la région.[4]

Le Cambodge suit la voie d'un développement économique classique : la part de la contribution au PIB du secteur agricole s'est réduite alors que l'industrie manufacturière et les services sont maintenant au cœur de la croissance de l'économie. La distribution spatiale de l'infrastructure économique du Cambodge tend à se concentrer dans des zones urbaines et péri-urbaines et le capital productif et la croissance des actifs est plus lente dans les zones rurales. Le concept d'économies d'agglomération[5] explique cette préférence géographique pour les villes : les biens et les services sont produits plus efficacement dans les zones les plus densément peuplées qui offrent un réservoir de main-d'œuvre qualifiée et un réseau d'entreprises aux activités complémentaires. Ces entreprises sont à la fois des producteurs et des créateurs d'une masse importante de clients. Leur concentration favorise aussi une compétition saine, engendrant une meilleure qualité et diversité de services, à des prix plus équilibrés.

Au niveau mondial, les chiffres révèlent également que les zones urbaines génèrent 55% du produit national brut dans les pays à faible revenu et 73% dans les pays à revenu intermédiaire.[6] Phnom Penh est certainement l'une des villes qui contribue majoritairement au PIB national. Trois des quatre piliers de la croissance qui ont alimenté l'économie cambodgienne au cours des vingt dernières années (le bâtiment, la confection et l'industrie manufacturière, les services et le tourisme) concentrent la majorité de leurs activités à Phnom Penh et dans d'autres grandes villes secondaires.

LES VILLES, LA TECHNOLOGIE ET LA TRANSFORMATION DES DONNÉES

La technologie permet une meilleure gestion du développement urbain. Les données générées par des individus et captées par de nouveaux moyens technologiques, tels que les réseaux d'infrastructures numériques, transforment la manière dont les villes sont gérées dans les économies en développement. Cette « révolution des données » a principalement lieu dans les centres urbains. A Phnom Penh, on remarque l'émergence de centres de données (il s'agit principalement d'entités privées qui collectent, directement ou indirectement et à des fins privées, les données de leur base de clients/consommateurs) gérés par des sociétés locales ou internationales. Peu de grandes entreprises d'analyse des données ont pénétré le marché cambodgien au cours des dernières années. Jusqu'à maintenant, le « big data » ne sert qu'à des fins commerciales, principalement pour mieux comprendre le comportement des clients dans des secteurs spécifiques (la banque, la finance, la téléphonie, les transports, etc.). Il est peut-être prématuré de parler d'une révolution des données au Cambodge[7] : la collecte et l'analyse des données en sont encore à leurs débuts puisque les infrastructures existantes restent limitées et que les systèmes de législation et de gouvernance sont en train d'émerger. Le potentiel des mégadonnées ne peut être exploité sans intelligence artificielle et la capacité d'exploitation des données combinées avec les dernières infrastructures de technologies numériques (l'IdO). Mais le concept de « villes intelligentes » deviendra vite une réalité omniprésente.



Phnom Penh : des transports collectifs informels à l'utilisation d'une application de son smartphone « PassApp » ou « Grab » pour commander son chauffeur.

Phnom Penh: informal public transport based on a "PassApp" or "Grab" application to book a ride.

ភ្នំពេញ៖ មធ្យោបាយដឹកជញ្ជូនសាធារណៈ:ឯកជនប្រើកម្មវិធីទូរស័ព្ទដៃដើម្បីហៅកង់បី ឬតាក់ស៊ី "PassApp" ឬ "Grab"

Des innovations technologiques majeures ont déjà été déployées et ont développé de nouveaux services urbains. Prenons l'exemple de Grab, une entreprise en Asie du Sud-Est qui a modifié le marché par l'apport d'une technologie nouvelle. L'entreprise a rapidement transformé l'accès des résidents de Phnom Penh aux services de transport. Avant Grab, peu d'acteurs-pionniers avaient pénétré le marché (il y avait notamment PassApp, l'entreprise cambodgienne de mise en contact d'utilisateurs avec des conducteurs) et leur accès au financement, aux technologies et à l'expertise était local et donc plus restreint.

De nouvelles plateformes d'échange soutenues par Facebook ont généré des réseaux additionnels de vente et de distribution à Phnom Penh.[8] Toutes ces innovations technologiques transforment les économies urbaines et les comportements sociaux en créant de nouveaux marchés et en devenant des solutions grand public accessibles à un large éventail de la population urbaine.

Des entreprises technologiques locales qui associent l'entreprenariat social aux innovations technologiques ont aussi fait leur apparition à Phnom Penh. Ces acteurs cherchent à résoudre des problèmes générés par la ville en améliorant l'efficacité d'un service déjà fourni (tel que la récupération des déchets ou les systèmes de transport en commun) ou en créant des services qui répondent à de nouveaux problèmes (tel qu'améliorer

Sur le chantier de la tour Canadia, 2007.

On the Canadia Tower construction site, 2007.

ការដ្ឋានសំណង់អគារកាណាឌីយ៉ា ឆ្នាំ២០០៧

© Cambodge Nouveau

Chantier de construction d'un *borey* sur la presqu'île de Chrui Changvar.

Borey construction site on the Chrui Changvar peninsula.

ការដ្ឋានដំណង់បុរីមួយកន្លែងនៅជ្រោយចង្វារ

l'accessibilité pour les personnes en situation de handicap). Leur objectif n'est pas de remplacer le service public ou de concurrencer des exploitants privés. Ils opèrent dans des niches de marché pour résoudre des problèmes urbains spécifiques à un coût abordable en accord avec les principes de fonctionnement des entreprises sociales.

La technologie et les données sont en mesure d'avoir un effet sur les opportunités économiques et l'amélioration des services sociaux, contribuant ainsi directement aux économies urbaines dynamiques.

Si des nouvelles formes de vulnérabilité urbaine menacent le modèle de croissance économique de Phnom Penh, il faut présenter les grandes tendances qui résultent de cette transformation urbaine en cours.

LES TENDANCES DE TRANSFORMATION URBAINE

La construction des *borey* est une des forces motrices de l'expansion urbaine[9] de Phnom Penh depuis la fin des années 1990. Il s'agit de nouvelles formes de résidences péri-urbaines construites par des promoteurs privés, majoritairement cambodgiens. Certains *borey* permettent une nouvelle mixité sociale à l'intérieur de la ville. La densité de population et le l'augmentation du prix des terrains associées au développement d'une réelle classe moyenne urbaine engendrent la multiplication des résidences fermées, particulièrement à la périphérie de Phnom Penh. Certains de ces projets deviennent des mégaprojets, s'étendant sur de très vastes surfaces. Ces résidences fermées et privées construites dans des pays en développement sont souvent accusées de créer des « élites » et de rassembler les ménages les plus riches, menant ainsi à l'existence de « ghettos pour les riches ». A Phnom Penh, les résidences privées ont certaines de ces caractéristiques. Leur plan masse est celui d'un lotissement de maisons standardisées encloses de murs qui délimitent le terrain de la communauté, leur accès est sécurisé et contrôlé et les services sont privés et gérés par une administration centrale privée. Mais les résidences privées cambodgiennes ne rassemblent pas forcément que l'élite.

Le groupe Peng Huoth, promoteur immobilier, leader du marché, s'est attaché à la qualité des espaces de vie, de l'architecture intérieure des maisons et de leur environnement, des espaces extérieurs et de loisirs. Le plan initial prenait exemple sur des modèles réussis de résidences fermées en Asie du Sud-Est mais en les adaptant aux besoins sociaux et culturels cambodgiens. La diversité des types et des tailles de logements proposés aux résidents a permis de réunir dans un même espace géographique des classes socio-économiques différentes, allant de familles très aisées à des foyers de la classe moyenne. La diversité de profils, de métiers, de niveaux de revenu, d'âges, d'ethnicités et de types de ménage est unique et se doit d'être analysée et comprise davantage. Certains peuvent arguer que les disparités de revenu et de richesse perdurent dans la résidence fermée, mais la réussite de ses créateurs, dont l'intention et la vision étaient de garantir une meilleure diversité sociale et un environnement agréable avec une densité élevée d'espaces verts pour répondre aux besoins des cambodgiens, a été démontrée par l'expansion de leurs projets et de leurs résidences. La qualité des services fournis aux résidents est également différente, avec plus d'égalité d'accès et des prestations de meilleure qualité pour tous, quelles que soient la classe sociale et le statut. Les règles internes qui sont imposées ont une influence sur les comportements individuels et collectifs des membres de la résidence, ce qui a permis de définir ce qu'est une communauté respectueuse et sûre. Cela a peut-être permis de mieux comprendre collectivement ce que peut être un quartier cambodgien. Alors que des comportements de plus en plus individualistes se remarquent dans le centre-ville, tels que l'usage abusif de l'espace public pour satisfaire des besoins privés et la résolution de conflits via le pouvoir social et l'autorité), un véritable civisme émerge dans ces communautés.[10] Le défi sera de maintenir ou d'accroître la diversité sociale et la qualité des services dans le temps.

La deuxième tendance démontre que les économies urbaines des villes cambodgiennes peuvent accélérer l'égalité des genres. Puisque le premier

Les *boreys* du groupe Peng Huoth ont fait le choix de donner une grande place à la nature.

Boreys built by the Peng Huoth group include extensive space for nature.

បុរីក្រុមហ៊ុន ប៉េង ហួត ផ្តល់សារៈសំខាន់ដល់ការធ្វើសួននិងដាំដើមឈើ

© Lim Bunhok

facteur de migration des zones rurales vers les zones urbaines est l'emploi, la capitale cambodgienne et plusieurs villes primaires ou secondaires attirent telles des aimants une large population rurale d'hommes et de femmes. Une étude récente[11] énumère différents facteurs explicatifs. La vie urbaine, en comparaison de la vie en zone rurale, impose des dépenses plus élevées (coût du logement, du transport) et de nombreux coûts masqués (énergie, santé, etc.). En même temps, les revenus possibles sont eux aussi plus élevés, à la fois en terme d'opportunités et de paie journalière et mensuelle. Les coûts d'opportunités économiques pour les femmes vivant dans une zone urbaine et qui ne visent pas les activités les plus génératrices de revenus sont bien plus élevées que dans les zones rurales. Ceci mène à un changement lié à des divisions du travail genrées plus claires, ce qui attribue aux femmes un rôle de création de revenus encore plus important. Un deuxième constat concerne la façon dont le contexte urbain façonne différemment les modèles sociaux et culturels de comportement entre femmes et hommes. Les femmes sont plus sollicitées par des opportunités professionnelles variées, ce qui leur permet de démontrer qu'elles ont des compétences et qu'elles peuvent rivaliser avec les hommes dans plusieurs secteurs économiques (comme l'industrie du vêtement ou du service). Ceci a permis un changement dans les perceptions, les statuts et les normes liés au genre. Phnom Penh a aussi rendu possible une évolution chez les jeunes cambodgiens dans leur perception des communautés LGBTQ+[12] et les obstacles auxquelles ces groupes font face. Malgré certains progrès, de forts préjugés et stéréotypes demeurent : les communautés LGBTQ+ sont encore écartées des services sociaux et de santé, de l'éducation et du monde du travail formel.[13] Une recherche de terrain approfondie permettrait de déterminer comment la ville peut jouer un rôle plus actif en offrant à tous des lieux plus sûrs et vivables.

1. *Cities: Engines of Growth and Prosperity for Developing Countries?*, Gilles Duranton, 2008.

2. La Banque mondiale a également analysé ce concept en 1998.

3. *Relocating labour-intensive manufacturing firms from China to Southeast Asia a preliminary investigation.* Chun Yang, 2016.

4. Les systèmes de préférences commerciales tels que le SGP aux Etats-Unis, les accords multifibres ou «Tout sauf les armes» dans l'Union européenne ont créé des conditions économiques très favorables pour les investisseurs qui ciblent des grands marchés d'exportation.

5. *Agglomeration economies and evolving urban form.* Genevieve Giuliano, Sanggkyun Kang, Quan Yuan, The Annals of Regional Science, 2019.

6. Nations Unies, Département des affaires économiques et sociales et Programme des Nations unies pour le développement, Rapport du forum mondial de la gouvernance locale et des services sociaux pour tous, 2000.

7. En décembre 2019

8. *Infrastructure as Creative Action: Online Buying, Selling, and Delivery in Phnom Penh.* Margaret Jack, Jay Chen, Steven J. Jackson. May 2017

9. *The Production of Urban Spaces in Phnom Penh.* Gabriel Fauveaud, 2015.

10. Ce paragraphe se réfère au projet Borey Peng Huoth Boeung Snour project sur la route nationale 1. Les données ont été récoltées lors d'entretiens réalisés par le Centre pour les études Khmer en 2019 auprès de résidents locaux de *borey* (échantillon d'environ 70 personnes sur une période de neuf mois) et avec l'un des fondateurs du groupe Peng Huoth.

11. *How Cities Erode Gender Inequality: A New Theory and Evidence from Cambodia,* Alice Evans, CID Faculty Working Paper No. 356, July 2019

12. Cet acronyme désigne les personnes lesbiennes, gays, bisexuelles, transgenres, et queer. Le plus (+) se réfère notamment aux individus qui interrogent leur identité sexuelle actuelle ainsi qu'aux personnes intersexes et asexuelles.

13. Salas V & Srun S. *An Exploration of Social Exclusion of Lesbians, Gay and Transgender Persons in Families and Communities and their ways of coping.* 2014 Social Protection Coordination Unit, SPCU-CARD, Phnom Penh.

How much can dynamic urban economies be a vector for social progress in Cambodian Cities?

What is the first noticeable aspect that demonstrates the development of a country? Its cities' growth. The expansion of a city, its infrastructure and the transformation of urban services are prime visible aspects of a growing economy, fueled by incoming domestic and international investments.

BY NATHAROUN NGO

WHY CITIES ARE DYNAMIC ENGINES OF GROWTH

The economic opportunities offered by globalization are much greater in cities, and this is particularly true in the context of developing countries such as Cambodia and cities such as Phnom Penh.

Economies are often analyzed at country-level only (GDP and business performance, macroeconomic and fiduciary stability, trade flows, migration policies, etc.). This level of analysis was dominant in most policy and economic analysis over the last 4 decades. It is only recently (past 5-10 years) that policy analysis and academic research has used cities as indicators to measure economic performances. Increasing capacity to collect and analyze disaggregated data at local level, combined with the growing importance given to cities may have paved the way. Increasing urbanization rates at global level have become a major transformative force that must be well managed by local government. This is even more critical in graduating economies, as cities in developing countries are places where growth concentrates. This directly impacts the livelihood opportunities of its inhabitants, while also predetermining the quality of their living conditions.

In Cambodia, transformation and growth in Phnom Penh over the past 10 years has clearly reflected one of the fastest growing economies in the world. The concept of cities as engines of growth[1, 2] is now a recognized part of mainstream knowledge, as local governments try to maximize opportunities offered by urban growth.

The intensification of manufacturing facilities (using labor intensive production) relocating out of China and other Asian countries due to higher wages, and the restructuring of regional supply chains have further accelerated industrialization[3], which has in turn accelerated urbanization processes in the Phnom Penh region. With low-cost manufacturing capacities and the presence of a young labor force, Cambodia is still among the preferred relocation sites in the region .

Cambodia follows a classic economic development path: the share of its agricultural sector's contribution to GDP decreased, while manufacturing and services are now central to economic

1. C13. Cities: Engines of Growth and Prosperity for Developing Countries? Gilles Duranton, 2008.

2. The World Bank also studied the concept in 1998.

3. Relocating labour-intensive manufacturing firms from China to Southeast Asia a preliminary investigation. Chun Yang, 2016

growth. The spatial distribution of Cambodia's economic infrastructure tends to concentrate within urban and peri-urban areas, and physical capital and asset growth is less rapid in rural areas. This geographical preference toward cities is well explained by the concept of "agglomeration economies[5]": goods and services are produced most efficiently in densely populated areas which offer access to a pool of skilled labor, and a network of firms with activities that complement each other. Those firms can act as suppliers, while contributing to create a critical mass of customers. The concentration of businesses also stimulates positive competition, improving the quality of services, diversity and price affordability. Zooming out to global scale, figures also show that urban areas generate 55% of gross national product in low-income countries, and 73% in middle-income countries[6]. Phnom Penh is certainly one of the main contributing cities to national GDP figures. Three of the four growth drivers that have fueled Cambodia's economy over the last 20 years (construction; garment, manufacturing and services; tourism) have most of their activities concentrated in Phnom Penh and major secondary cities.

CITIES, TECHNOLOGY AND DATA TRANSFORMATION

Technology is leading to better management of urban development. Data generated by individuals and captured by new technological means, such as digital infrastructure networks, is transforming the way cities are managed in developing economies. This "data revolution" mainly occurs in urban centers. In Phnom Penh, we are witnessing the emergence of data centers (mostly private entities that directly or indirectly collect data from its customer/consumer base for private purposes) managed by local and international companies. Only a few big data analytical companies have entered the Cambodian market in recent years. At present, "big data" only serves business purposes, mainly to better understand customer behaviors in specific sectors (banking and finance, telcos, transport etc.). It may be premature to speak of a data revolution in Cambodia[7], as data collection and analysis is still in its infancy stage due to limited existing infrastructure and nascent legislation/governance systems. The potential of big data can't be unlocked without AI and data mining capabilities, combined with the latest digital technologies infrastructure (IoT). But it is only a matter of time before the "smart cities" concept turns into a pervasive reality.

Powerful urban tech innovators have already deployed and scaled-up new urban technology services. Grab, for instance, a well-known company in Southeast Asia, has been both a market and technology disruptor. The company has rapidly transformed the way Phnom Penh's residents access transportation services. A few other pioneer-actors entered the market before Grab (such as Cambodian ride hailing company Pass'App), but their access to funding, technologies, and expertise was local and therefore more restricted.

Facebook supported new online trading platforms have created additional sales and distribution networks in Phnom Penh[8]. All these new technological innovations are transforming urban economies and social behaviors, by creating new markets and becoming mainstream solutions accessible to a wide range of urban populations.

Phnom Penh has also seen the emergence of a local "tech scene" that combines social entrepreneurship and technological innovations. Those actors seek to address urban generated issues by either improving the efficiency of an existing service (e.g. solid waste collection, public transport systems), or by creating new services that address emerging issues (better access for disabled people). Their aim is not to replace public service capacities or compete with private operators. They operate in niche markets to help solve specific urban issues, while delivering a service with an affordable fee, in line with the operating principles of social enterprises.

Technology and data have demonstrated capacity to serve both economic opportunities and social service improvement, thereby directly contributing to dynamic urban economies.

While new forms of urban vulnerabilities may threaten Phnom Penh's long-term economic growth model, it is important to mention some major trends that result from the ongoing urban transformation.

URBAN TRANSFORMATION TRENDS.

One major driving force of urban expansion[9] in Phnom Penh since the end of the 1990s is the construction of *borey*, i.e. new form of peri-urban housing community projects built by private developers, mainly Cambodian. Some of those *borey* are producing a new social mix within the city. Increasing population density and land prices, associated with the development of a solid urban middle class, is leading to the proliferation of gated communities particularly on the periphery of Phnom Penh. Some of those projects are becoming mega-projects, spreading across large areas of land. Theses gated communities in developed countries are often depicted negatively as creating a class of wealthy elites, living a segregated existence in "ghettos for the rich". However, Cambodian gated communities possess some of these characteristics in Phnom Penh. In design, they consist of clusters of "standardized" houses surrounded by walls that form the boundary of the community with controlled security access and private services regulated by a central private authority. Cambodian gated communities do not all consist of similar clusters of social "elites".

A Cambodian real estate developer, one of the market leaders, Peng Huoth Group, has managed this concept differently. It has focused on places that offer high quality, both in terms of interior architecture and the exterior environment and recreation areas. The initial master plan emulated successful gated community models in the Southeast Asia region but adapted them to Cambodian social and cultural needs. By offering residents diversity in both the type and size of housing, it has brought together within the same geographical space, different socio-economic classes, ranging from high net worth families to middle-income households. The variety of profiles, occupations, revenue levels, age groups, ethnicities, and household types is quite unique and merits further research. One can argue that income and wealth disparities remain within the gated community, but the intention and vision of its creators to ensure greater social diversity and a pleasant living environment, and to meet the needs of local people with more generous green spaces, have been successfully demonstrated by the growth of their projects and communities. The quality of services provided to community residents, with more equal access and better-quality provision for all, and to meet the needs of local people with more generous green spaces, social classes and status, is also different. The enforcement of internal rules and regulations influences individual and collective behaviour in the community, leading to a stronger sense of what a respectful and safe community is. It may have given rise to a new collective understanding of what a Cambodian neighborhood could look like. By contrast with the prevalence of increasingly individualistic behaviours in the city centre, measured by the sometimes disruptive use of public spaces for private purposes and the use of social power on the authority to resolve conflict, genuinely civic attitudes are emerging[10]. The challenge will be to maintain or increase this social diversity and service quality over time.

From another perspective, urban economies in Cambodian cities can be seen as a catalytic force for gender equality. As the first driver of rural to urban migration is employment, the capital city and several primary or secondary cities act as magnets and attract large rural male and female populations. A recent study[11] identifies some interesting factors associated with this trend. By comparison with rural life,

urban living undoubtedly demands greater household expenditure to cover accommodation and transportation costs, as well as hidden factors (energy, health, etc.). At the same time, the work opportunities are also greater, and therefore the potential for higher incomes. The economic opportunity costs for women not seeking the best income generating activities while living in an urban area are much higher than in rural areas. This has produced a shift in traditional gender divisions of labour, and given women and even more important role in income generation. The second factor concerns the way in which urban conditions shape social and cultural models relating to the relations between women and men. The increased exposure to various working opportunities enables women to clearly demonstrate that they have skillsets and professional competencies and that they can easily compete with men in several economic sectors (such as in garment or services sector). This has directly contributed to a shift in gender -related perceptions of status and norms. Phnom Penh has also enabled young Cambodians to become increasingly aware of LGBTQ+[12] communities and the challenges they face. Despite progress, strong negative biases and stereotypes remain; LGBTQ+ communities still experience exclusion from social and health services, education and the formal workforce[13]. More in-depth field research is needed to define how a city can play a more active role in providing all with safer and more livable spaces.

4. Preferential economic cooperation and trade schemes such as the US Generalized System of Preference and Multi-Fiber agreement, and the EU Everything But Arms (EBA) have created very favorable economic conditions for investors targeting large export markets.

5. Agglomeration economies and evolving urban form. Genevieve Giuliano, Sanggkyun Kang, Quan Yuan, The Annals of Regional Science, 2019.

6. United Nations, Department for economic and social affairs and the United Nations Development Program, Report of the United Nations Global Forum on Local Governance and Social Services for All, 2000.

7. As of December 2019

8. Infrastructure as Creative Action: Online Buying, Selling, and Delivery in Phnom Penh. Margaret Jack, Jay Chen, Steven J. Jackson. May 2017

9. The Production of Urban Spaces in Phnom Penh. Gabriel Fauveaud, 2015.

10. Reference is made within this paragraph to Borey Peng Huoth Boeung Snour project, located on National Road Number 1. The data derives from direct short interviews made by the Center for Khmer Studies in 2019 with local borey residents (sample size of around 70 people over a period of 9 months) and with one of the founders of the Peng Huoth Group.

11. How Cities Erode Gender Inequality: A New Theory and Evidence from Cambodia, Alice Evans, CID Faculty Working Paper No. 356, July 2019

12. LGBTQ+ is an acronym that designates lesbian, gay, bisexual, transgender, and queer. Plus (+) refers to individual questioning their current sexual identity, intersex, and asexual people.

13. Salas V & Srun S. An Exploration of Social Exclusion of Lesbians, Gay and Transgender Persons in Families and Communities and their ways of coping. 2014 Social Protection Coordination Unit, SPCU-CARD, Phnom Penh.

© Phnom Penh Post

Phnom Penh : transport collectif informel des ouvriers en camion.

Phnom Penh: informal truck transport for workers.

ភ្នំពេញ៖ មធ្យោបាយដឹកជញ្ជូនសាធារណៈ:ឯកជន ឡានទ្រុងដឹកកម្មករ

កម្លាំងសេដ្ឋកិច្ចក្រុង៖ តើជាកត្តាមួយនៃភាពចម្រុងចម្រើនសង្គមនៅក្នុងទីក្រុងកម្ពុជាឬទេ ?

តើអ្វីទៅជាសញ្ញាសំគាល់ដំបូងគេនៃការអភិវឌ្ឍរបស់ប្រទេសមួយ ? គឺកំណើននៅក្នុងទីក្រុង។ ការពង្រីកទីក្រុង ហេដ្ឋារចនាសម្ព័ន្ធក្រុង និងរូបបរិវត្តន៍នៃសេវាកម្មក្រុង ទាំងអស់នេះសុទ្ធតែជាសូចនាករសំខាន់ៗ សម្រាប់វាស់វែងកំណើនសេដ្ឋកិច្ចមួយ ដែលអាចមានទៅបាន ដោយការវិនិយោគក្នុងស្រុក និងការវិនិយោគអន្តរជាតិ។

ដោយលោក ង៉ោ ណត្ថរុន

នៅក្នុងរយៈពេល១៥ឆ្នាំ ទីក្រុងភ្នំពេញបានផ្លាស់ប្តូរទ្រង់ទ្រាយ

ហេតុអ្វីបានជាទីក្រុងគឺជាកម្លាំងចលករនៃកំណើន ? កាលនុវត្តភាពសេដ្ឋកិច្ចដែលអាចកើតមានឡើងបានដោយសារសាកលភាវូបនីយកម្ម ពិតជាមានច្រើននៅក្នុងទីក្រុង ហើយរឿងបែបនេះរឹតតែត្រឹមត្រូវថែមទៀត ជាពិសេស នៅក្នុងបណ្តាប្រទេសដែលកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជា និងក្នុងទីក្រុងនានា ដូចជាទីក្រុងភ្នំពេញនេះជាដើម។

ជាទូទៅ សេដ្ឋកិច្ចត្រូវបានវិភាគតែក្នុងកម្រិតប្រទេសតែប៉ុណ្ណោះ ដោយពិនិត្យមើលផលិតផលក្នុងស្រុកសរុប ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពធនប័ត្រ រំហូរពាណិជ្ជកម្ម និងនយោបាយទេសន្តរប្រវេសន៍ជាដើម។ គេប្រើនធ្វើការវិភាគបែបនេះ ជាជាងការវិភាគនយោបាយសេដ្ឋកិច្ច នៅក្នុងរយៈពេល៨ទសវត្សរ៍ចុងក្រោយនេះ។ កាលពីពេលថ្មីៗ ពោលគឺក្នុងរយៈពេលពី៥ទៅ១០ឆ្នាំចុងក្រោយនេះ ការងារវិភាគនយោបាយ និងការងារសិក្សាស្រាវជ្រាវ បានយកទីក្រុងជាសូចនាករសម្រាប់វាស់វែងគុណវុឌ្ឍិសេដ្ឋកិច្ច។ ការផ្លាស់ប្តូរវិធីសាស្ត្រនេះអាចពន្យល់បានដោយសមត្ថភាពកាន់តែខ្លាំងឡើងនៃការប្រមូល និងវិភាគទិន្នន័យបាន តាំងពីកម្រិតមូលដ្ឋានឡើងទៅ បូកផ្សំនឹងការផ្តោតការចិត្តទុកដាក់កាន់តែខ្លាំងឡើងទៅលើទីក្រុង។ កំណើនអត្រានគរូបនីយកម្មក្នុងកម្រិតពិភពលោក បានក្លាយទៅជាកម្លាំងនៃរូបបរិវត្តន៍ចំបងមួយ ដែលរដ្ឋាភិបាលត្រូវតែគ្រប់គ្រងឲ្យបានល្អ។ ចំណុចនេះរឹតតែសំខាន់ ថែមទៀត

សម្រាប់សេដ្ឋកិច្ចដែលកំពុងអភិវឌ្ឍន៍ ដោយសារថា កំណើននេះ ភាគច្រើន គឺមានតែនៅក្នុងទីក្រុងប៉ុណ្ណោះ។ កំណើននេះផ្តល់ផលជះផ្ទាល់ទៅលើប្រភពចំណូលរបស់ប្រជាពលរដ្ឋ និងថែមទាំងជាកត្តាកំណត់គុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទៀតផង។

នៅកម្ពុជា រូបបរិវត្តន៍ និងកំណើនរបស់រាជធានីភ្នំពេញ នៅក្នុងទសវត្សរ៍ចុងក្រោយនេះ គឺអាចប្រៀបធៀបបានទៅនឹងរូបបរិវត្តន៍នៅតាមបណ្តាប្រទេសផ្សេងទៀតក្នុងពិភពលោក ដែលធ្លាប់មានកំណើនសេដ្ឋកិច្ចលឿនបំផុត។ ទស្សនាទានដែលយកទីក្រុងជាក្បាលម៉ាស៊ីននៃកំណើន[1,2] បច្ចុប្បន្ននេះ ត្រូវបានគេប្រើប្រាស់ជាទូទៅយ៉ាងទូលំទូលាយ ពីព្រោះថា រដ្ឋាភិបាលខិតខំបង្កើនឲ្យបានអប្បរមានូវកុលានុវត្តភាពដែលផ្តល់ដោយកំណើនទីក្រុង។

បាតុភូតដែលរោងចក្រ (ជាវិស័យប្រើកម្លាំងពលកម្មច្រើន) ចាកចេញកាន់តែច្រើនពីប្រទេសចិន និងពីបណ្តាប្រទេសអាស៊ីផ្សេងទៀតដោយសារតែប្រាក់ខែកម្មករនៅប្រទេសទាំងនោះកាន់តែខ្ពស់ និងការរៀបចំរចនាសម្ព័ន្ធឡើងវិញនូវខ្សែបណ្តាញផ្គត់ផ្គង់ថ្នាក់តំបន់ បានពន្លឿនឧស្សាហកម្ម ភាវូបនីយកម្ម[3] ហើយបន្ទាប់មក បានពន្លឿនដំណើរការនគរូបនីយកម្មក្នុងតំបន់ជាយទីក្រុងភ្នំពេញ។ ដោយមានសមត្ថភាពផលិតក្នុងតម្លៃថោក និងមានកម្លាំងពលកម្មវ័យក្មេង ប្រទេសកម្ពុជាបានក្លាយជាគោលដៅនៃការប្តូរមកបង្កើតរោងចក្រវិនិយោគ ដែលគេចូលចិត្តជាងគេនៅក្នុងតំបន់[4] ។

ប្រទេសកម្ពុជាដើរតាមផ្លូវអភិវឌ្ឍន៍សេដ្ឋកិច្ចតាមរបៀបធម្មតា មានន័យថា ភាគនៃការរួមចំណែកដល់ការបង្កើតផលិតផលក្នុងស្រុកនៃ វិស័យកសិកម្មត្រូវបានកាត់បន្ថយ ខណៈឧស្សាហកម្មកែច្នៃ និងវិស័យសេវាកម្ម បច្ចុប្បន្ននេះ ស្ថិតនៅចំបេះដូងនៃកំណើនសេដ្ឋកិច្ច។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ច្រើនតែផ្តោតទៅលើតំបន់ក្រុង និងតំបន់ជាយក្រុង រីឯមូលធនផលិតកម្ម និងកំណើនទ្រព្យសកម្ម[6] នៅតាមតំបន់ជនបទ មិនសូវលឿនទេ។ ទស្សនាទានសេដ្ឋកិច្ចតំបន់ទីប្រជុំជនគឺជាកត្តាពន្យល់អំពីចំណង់ចំណូលចិត្តនៃការវិនិយោគនៅក្នុងទីក្រុង មានន័យថា ផលិតកម្មទ្រព្យសម្បត្តិ និងសេវាកម្មនៅទីក្រុង គឺមានប្រសិទ្ធភាពជាងនៅ ជនបទ ហើយកន្លែងដែលមានប្រជាជនរស់នៅច្រើន គឺជាឃ្លាំងផ្តល់កម្លាំងពលកម្មប្រកបដោយគុណភាព និងខ្សែបណ្តាញសហគ្រាស ដែលប្រកបអាជីវកម្មបំពេញគ្នាទៅវិញទៅមក។ សហគ្រាសទាំងនេះ អាចដើរតួនាទី ជាអ្នកផ្គត់ផ្គង់ផង ជាប្រភពបង្កើតអតិថិជនចំនួនដ៏ច្រើនផង។ ការប្រមូលផ្តុំយ៉ាងច្រើននៃសហគ្រាសទាំងអស់នៅក្នុងតំបន់តែមួយ ក៏ជួយជម្រុញផងដែរឲ្យមានការប្រកួតប្រជែងត្រឹមត្រូវ នាំមកនូវសេវាកម្មប្រកបដោយគុណភាពនិង សម្សរបែប ក្នុងតម្លៃកាន់តែមានតុល្យភាពថែមទៀត។

នៅក្នុងកម្រិតពិភពលោក តួលេខបង្ហាញផងដែរថា តំបន់ក្រុងបង្កើត ៥៥%នៃផលិតផលជាតិសរុប នៅក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប និង៧៣%នៅក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលមធ្យម[5]។ ភ្នំពេញប្រាកដជាទីក្រុងមួយក្នុងចំណោមបណ្តាទីក្រុង ដែលរួមចំណែកភាគច្រើនទៅក្នុងផលិតផលជាតិសរុប។ សសរស្តម្ភបីក្នុងចំណោមសសរស្តម្ភទាំងបួននៃកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ គឺមានវិស័យសំណង់ វិស័យកាត់ដេរនិងឧស្សាហកម្មកែច្នៃ វិស័យសេវាកម្ម និងវិស័យទេសចរណ៍។ វិស័យផ្តល់កំណើនទាំងនេះផ្តោតភាគច្រើនទៅលើសកម្មភាពជុរកិច្ចនៅទីក្រុងភ្នំពេញ និងនៅតាមបណ្តាទីក្រុងធំៗបន្ទាប់ផ្សេងទៀត។

ទីក្រុង បច្ចេកវិទ្យា និងរូបបរិវត្តន៍នៃទិន្នន័យ

បច្ចេកវិទ្យាអនុញ្ញាតឲ្យការគ្រប់គ្រងការអភិវឌ្ឍក្រុងប្រព្រឹត្តិទៅបានប្រសើរជាងមុន។ ទិន្នន័យដែលបង្កើតឡើងដោយបុគ្គល និងប្រមូលបានដោយមធ្យោបាយបច្ចេកវិទ្យាថ្មីៗ ដូចជាបណ្តាញហេដ្ឋារចនាសម្ព័ន្ធឌីជីថល ធ្វើឲ្យមានការផ្លាស់ប្តូររបៀបនៃការគ្រប់គ្រងទីក្រុង នៅក្នុងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍។ "បដិវត្តន៍ទិន្នន័យ" នេះ កើតឡើងជាពិសេស នៅក្នុងតំបន់ទីប្រជុំជន។ នៅភ្នំពេញ គេសង្កេតឃើញមានមជ្ឈមណ្ឌលទិន្នន័យ (ភាគច្រើនគឺជាក្រុមហ៊ុនឯកជន ដែលប្រមូលយកដោយផ្ទាល់ ឬដោយប្រយោល ឬសម្រាប់ប្រយោជន៍ឯកជន នូវទិន្នន័យពាក់ព័ន្ធនឹងអតិថិជន ឬអ្នកប្រើប្រាស់របស់ខ្លួន) ដែលគ្រប់គ្រងដោយក្រុមហ៊ុនក្នុងស្រុក ឬក្រុមហ៊ុនអន្តរជាតិ។ មានក្រុមហ៊ុនវិភាគទិន្នន័យធំៗតិចណាស់ ដែលបានជ្រៀតចូលក្នុងទីផ្សារកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ រហូតដល់បច្ចុប្បន្ននេះ "ទិន្នន័យធំ" ត្រូវបានគេប្រើប្រាស់សម្រាប់តែប្រយោជន៍ពាណិជ្ជកម្មប៉ុណ្ណោះ ភាគច្រើន គឺដើម្បីស្វែងយល់ឲ្យបានកាន់តែប្រសើរជាងមុន អំពីឥរិយាបទរបស់អតិថិជន នៅក្នុងវិស័យពិសេសៗ ដូចជា វិស័យធនាគារ ហិរញ្ញវត្ថុ ទូរស័ព្ទ និងវិស័យដឹកជញ្ជូនជាងដើម។ ពេលនេះ ប្រហែលជាឆាប់ពេក ប្រសិនបើយើងនិយាយអំពីបដិវត្តន៍ទិន្នន័យនៅកម្ពុជា[7] ពីព្រោះថា ការប្រមូលនិងវិភាគទិន្នន័យ ទើបតែចាប់ផ្តើមប៉ុណ្ណោះ ហើយហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នៅមានកម្រិតនៅឡើយ។ ម្យ៉ាងទៀត ប្រព័ន្ធច្បាប់និងអភិបាលកិច្ច ទើបតែចាប់ផ្តើមមានប៉ុណ្ណោះ។ សក្តានុពលភាពនៃ "ទិន្នន័យធំ" មិនអាចត្រូវបានយកទៅប្រើប្រាស់ដោយគ្មានភាពឆ្លាតវៃសិប្បនិម្មិត និងដោយគ្មានសមត្ថភាពប្រើប្រាស់ទិន្នន័យ ផ្សារភ្ជាប់នឹងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាឌីជីថលចុងក្រោយឡើយ។ ប៉ុន្តែ វាគ្រាន់តែជារឿងពេលវេលាប៉ុណ្ណោះ មុននឹងទស្សនាទាន "ទីក្រុងឆ្លាតវៃ" ក្លាយជារឿងពិតគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។

នវានុវត្តភាពបច្ចេកវិទ្យាធំៗ ត្រូវបានប្រើប្រាស់រួចហើយ និងបានបង្កើតសេវាកម្មក្រុងថ្មីៗទៀតផង។ ជាឧទាហរណ៍ ក្រុមហ៊ុន Grab គឺជាក្រុមហ៊ុនមួយនៅអាស៊ីអាគ្នេយ៍ ដែលបានធ្វើឲ្យទីផ្សារដឹកជញ្ជូនមានការប្រែប្រួល តាមរយៈការនាំចូលនូវបច្ចេកវិទ្យាថ្មីមួយ។ ក្រុមហ៊ុននេះបានធ្វើឲ្យរបៀបទទួលបានសេវាកម្មដឹកជញ្ជូនរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងភ្នំពេញ បានផ្លាស់ប្តូរគួរឲ្យកត់សម្គាល់។ មុនក្រុមហ៊ុន Grab ចូលមកដល់ មានក្រុមហ៊ុនចាប់ផ្តើមរកស៊ីនៅកម្ពុជាក្នុងវិស័យនេះតិចតួចណាស់ (មានជាអាទិ៍ ក្រុមហ៊ុន PassApp ជាក្រុមហ៊ុនខ្មែរមួយ ដែលភ្ជាប់ទំនាក់ទំនងរវាងអ្នកប្រើប្រាស់ និងអ្នកបើកបរ) ហើយការទទួលបានហិរញ្ញប្បទាន បច្ចេកវិទ្យា និងជំនាញ របស់ក្រុមហ៊ុន PassApp នេះ មានកម្រិតត្រឹមក្នុងស្រុក ដូច្នេះក៏នៅមានកម្រិតដែរ។

ថ្នាលបណ្តូរថ្មីៗ ដែលគាំទ្រដោយ Facebook បានបង្កើតខ្សែរបណ្តាញលក់ដូរនិងចែកចាយបន្ថែមទៀតនៅទីក្រុងភ្នំពេញ[8]។ រាល់នវានុវត្តន៍បច្ចេកវិទ្យានេះ បាននាំមកនូវរូបបរិវត្តន៍សេដ្ឋកិច្ចទីក្រុង និងឥរិយាបទសង្គម ដោយបង្កើតទីផ្សារថ្មី និងបានក្លាយទៅជាដំណោះស្រាយសម្រាប់មហាជនទូទៅ ដែលភាគច្រើននៃប្រជាពលរដ្ឋរស់នៅក្នុងទីក្រុងងាយនឹងទទួលបាន។ ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងស្រុកដែលបូកបញ្ចូលសហគ្រិនភាពសង្គម និងនវានុវត្តភាពបច្ចេកវិទ្យា ក៏លេចមុខឡើងនៅក្នុងទីក្រុងភ្នំពេញដែរ។ ក្រុមហ៊ុនទាំងនេះ ខិតខំដោះស្រាយបញ្ហាដែលបង្ករឡើងដោយសារទីក្រុង តាមរយៈការកែលម្អប្រសិទ្ធភាពនៃសេវាកម្ម ដែលត្រូវបានផ្តល់ជូនហើយ ដូចជាការប្រមូលសំរាម ឬប្រព័ន្ធដឹកជញ្ជូនរួម ឬក៏ការបង្កើតសេវាកម្ម ដែលឆ្លើយតបទៅនឹងបញ្ហាថ្មីៗ ដូចជា កែលម្អសេវាដែលធ្វើឲ្យជនពិការក៏ងាយនឹងទទួលបានដូចគ្នា។ គោលដៅរបស់ក្រុមហ៊ុនទាំងនេះ មិនមែនជំនួសឲ្យសេវាសាធារណៈ ឬក៏ប្រកួតប្រជែងជាមួយក្រុមហ៊ុនឯកជននោះទេ ប៉ុន្តែក្រុមហ៊ុនទាំងនេះ ប្រតិបត្តិការនៅក្នុងចំណែកណាមួយនៃទីផ្សារ ដើម្បីដោះស្រាយបញ្ហាពិសេសៗនៅក្នុងក្រុងក្នុងតម្លៃមួយសមរម្យ ដោយអនុលោមទៅតាមគោលការណ៍នៃក្រុមហ៊ុនមានទំនួលខុសត្រូវសង្គម។

បច្ចេកវិទ្យានិងទិន្នន័យកំពុងតែអាចផ្តល់ផលជះទៅលើកាលានុវត្តភាពសេដ្ឋកិច្ច និងការកែលម្អសេវាកម្មសង្គម ដូច្នេះ ក็ួមចំណែកដោយផ្ទាល់ទៅក្នុងសេដ្ឋកិច្ចក្រុងប្រកបដោយថាមភាពផងដែរ។ ប្រសិនបើទម្រង់ថ្មីៗនៃតេទនីយភាពក្រុង គំរាមកំហែងដល់គំរូកំណើនសេដ្ឋកិច្ចទីក្រុងភ្នំពេញ គេត្រូវលើកឡើងអំពីទំនោរធំៗ ដែលកំពុងតែកើតចេញពីរូបបរិវត្តន៍ក្រុងនេះវិញ។

ទំនោរ និងរូបបរិវត្តន៍ក្រុង

ការសាងសង់បុរីគឺជាកម្លាំងចលករមួយនៃការពង្រីកទីក្រុងភ្នំពេញ[9] ចាប់តាំងពីដំណាច់ទសវត្សរ៍ឆ្នាំ១៩៩០មក។ បុរីគឺជាទម្រង់ថ្មីមួយនៃតំបន់រស់នៅជាយក្រុង កសាងឡើងដោយក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន ភាគច្រើនជាក្រុមហ៊ុនខ្មែរ។ បុរីខ្លះអនុញ្ញាតឲ្យមានការរស់នៅលាយឡំគ្នាក្នុងទីក្រុង។ ដង់ស៊ីតេប្រជាពលរដ្ឋ និងកំណើនតម្លៃដីធ្លី បូកផ្សំនឹងកំណើនអ្នកដែលមានធនធានមធ្យមក្នុងក្រុង បណ្តាលឲ្យមានការសាងសង់លំនៅដ្ឋានសម្រាប់ការរស់នៅបែបថ្មីមួយ ជាបុរីដែលមានរបងបិទជិត ហើយបុរីមានចំនួនកាន់តែច្រើនឡើង ជាពិសេស នៅតំបន់ជាយក្រុងភ្នំពេញ។ បុរីខ្លះបានក្លាយជាគម្រោងដ៏ធំ អភិវឌ្ឍលើផ្ទៃដីមួយយ៉ាងធំដែរ។ លំនៅដ្ឋានក្នុងបុរី ដែលមានរបងបិទជិតជាលក្ខណៈឯកជនទាំងនេះ ត្រូវបានគេសង្កេតឃើញមាននៅក្នុងបណ្តាប្រទេស

កំពុងអភិវឌ្ឍន៍ ហើយជាទូទៅ ត្រូវបានគេចោទថា ជាការបង្កើត "ក្រុងអ្នកមាន" និងប្រមូលផ្ទុំក្រុមគ្រួសារអ្នកមានជាងគេឲ្យរស់នៅជាមួយគ្នា ដូច្នេះ ក៏បង្កើតជាទីប្រជុំជនសម្រាប់ពួកអ្នកមាន។ នៅទីក្រុងភ្នំពេញ ក៏មានលំនៅដ្ឋានឯកជនមានលក្ខណៈបែបនេះខ្លះដែរ។ បុរីឌីហ្សាញសំណង់ផ្ទះដែលមានស្តង់ដារ មានរបងបិទជិត និងកំណត់ព្រំដីរបស់ម្ចាស់ផ្ទះនៅក្នុងសហគមន៍ មានអ្នកយាមត្រួតពិនិត្យការចេញចូល រីឯសេវាកម្មក៏មានលក្ខណៈឯកជនដែរ គ្រប់គ្រងដោយរដ្ឋបាលកណ្តាលឯកជនដែលជារបស់ម្ចាស់បុរី។ ប៉ុន្តែ បុរីខ្មែរមិនប្រាកដថាមានតែគ្រួសារអ្នកមានសុទ្ធសាធរស់នៅទេ។

